# ខែមុំស្ដី ស.ម.អា

# KhmerPost USA

Printing The Cambodian World News

VOL. 05 ISSUE 77 FEB. 11th–24th, 2011

សុបិន : (267) 253-3947, សែម : (781) 244-0522

MASSACHUSETTS
- LOWELL
- LYNN
- REVERE
- BOSTON

PENNSYLVANIA
RHODE ISLAND
NEW JERSEY



| មាតិការឿង | ទំព័រ |
|---|---|
| ១- ឃុវជនសហគមន៍ឡូវែល | ០២ |
| ២- កម្មវិធីជម្ងឺទឹកនោមផ្អែម | ០៤ |
| ៣- ព្រឹត្តិការណ៍អតីតចៅអធិការវត្តអង្គរជុំ | ០៥ |
| ៤- កិច្ចសម្ភាសន៍ឯកឧត្តម សមរង្ស៊ី | ០៦ |
| ៥- The Power To Make Social | ០៧ |
| ៥- The Cambodia Daily | ០៨ & ១៣ |
| ៦-សូមកុំជេរនាយករដ្ឋមន្ត្រីថា | ០៩ |


# ចូលឆ្នាំចិនឆ្នាំថ្មីនេះធ្វើយ៉ាងណា នឹងសុខសប្បាយ និងរកស៊ីមានបាន

2011 THE YEAR OF THE RABBIT HAPPY NEW YEAR

សែនក្នុងពិធីចូលឆ្នាំចិន

**កាលពីរដូវចូលឆ្នាំចិន ឆ្នាំ២០១០ ជនជាតិចិនទាំង ប្រុសទាំង ស្រីបានផ្តើលនាំគ្នារៀបការឆ្នាំថ្មីចូលមកដល់ដោយសារមានជំនឿថា លើរៀបការក្រោយពេលចូលឆ្នាំថ្មី គេនឹងក្លាយជាបុរសពោះម៉ាយ ឬស្ត្រីមេម៉ាយ ព្រោះរដូវវស្សាវែកដែលកន្លងផុតទៅជាង១០ថ្ងៃនឹងធ្វើឱ្យពួកគេអស់ឋាមពលពីក្នុងខ្លួន។ ចំពោះឆ្នាំ២០១១នេះ ពិធីបុណ្យចូលឆ្នាំចិនចាប់ផ្តើមពីថ្ងៃទី០២ បញ្ចប់នៅថ្ងៃទី ០៤ ខែកុម្ភៈ ដោយពុំមានការលេចឡើងពីជំនឿអ្វីមួយទាក់ទងទៅនឹងការចូលឆ្នាំថ្មីនោះទេ ។**

•••សមាគមចិនទាជីវនៅទីក្រុងភ្នំពេញបានអះអាងថាគ្មានអ្វីខុសពីធម្មតាទេ សម្រាប់ចូលឆ្នាំចិនឆ្នាំថ្មីនេះ ។ គឺមានពិធីសែនព្រេនបោសសំអាត តាំងលំអផ្ទះពិធីជួបជុំញាតិសន្តាន និងដើរកម្សាន្តតាមការឱយមរបស់ក្រុមគ្រួសារនីមួយៗជាធម្មតា។ ជារឿងរាល់ឆ្នាំពិធីបុណ្យចូលឆ្នាំចិនតែងតែធ្វើ ឡើងនៅរវាងចុងខែមករា ឬដើមខែកុម្ភៈជាដរាប។ សម្រាប់ឆ្នាំនេះ បុណ្យចូលឆ្នាំថ្មីចាប់ផ្តើមនៅថ្ងៃទី០២កុម្ភៈ ដែលត្រូវជាថ្ងៃសែន និងបញ្ចប់នៅថ្ងៃទី០៤ ខែកុម្ភៈ។ ជនជាតិចិនជាទូទៅជឿជាក់យ៉ាងមុតមាំលើជំនឿថា ការបានសែនព្រេនដល់អ្នកមានបុណ្យបារមីទាំងលើមេឃលើដី ជាពិសេស ជីដូនជីតា និងបុព្វបុរសរបស់គេនឹងអាចបំបាត់ភាពចង្រៃឧបទ្រពទាំងឡាយឱ្យវិនាសសាបសូន្យនៅក្នុងឆ្នាំចាស់អស់ ហើយនឹងនាំមកនូវភាពចម្រុងចម្រើនរកស៊ីមានបាននៅក្នុងឆ្នាំថ្មីវិញ ។

សកម្មភាពលោតម៉ុងសាយក្នុងពិធីចូលឆ្នាំចិន

តាមទម្លាប់ជនជាតិចិនគេត្រណមបំផុតនៅថ្ងៃទី១នៃថ្ងៃបុណ្យចូលឆ្នាំថ្មី ឬហៅថាថ្ងៃ "ឈី អ៊ិច"។ ក្នុងថ្ងៃនេះគេមិនឱ្យធ្វើអ្វីខូចខាតបាក់បែក ឬដើរលេងឆ្ងាយឡើយ ។ ប៉ុន្តែបន្ទាប់ពីនេះ គឺថ្ងៃទី២-៣ ទើបគេចេញធ្វើដំណើរទៅឆ្ងាយ។ ឬដើរសាកសួរសុខទុក្ខញាតិបងប្អូនរបស់ពួកគេ ។

**-តើនរណាជាអ្នកបង្កើតជំនឿការសែនព្រេននេះឡើង?**

ប្រពៃណីនេះមានខ្លះយល់ថា បានមកពីលិទ្ធិតៅដែល "ឡៅជឺ"ជាអ្នកបង្កើតឡើងមក។ ឡៅជឺ កើតមុនពុទ្ធសករាជចំនួន៦០ឆ្នាំ។ ឡៅជឺ បានសរសេរក្នុងគម្ពីរមួយមានឈ្មោះថា "តៅតិចកេង" ដែលជាគោលការសំខាន់របស់លទ្ធិតៅ ។ ពាក្យប្រៀនប្រដៅរបស់ ឡៅជឺ មានន័យថា កាន់តែឱ្យ កាន់តែមាន ដោយសារឡៅជឺ យល់ឃើញថា ការសែនព្រេនឬការបូជានោះ គ្មានប្រយោជន៍អ្វីទេ ហើយលោកថែមទាំងមិនបានគោរពបូជាព្រះឡើយ។ នៅពេល ឡៅជឺ បាត់បង់ជីវិត ឡៅជឺក៏បានទទួលការគោរពពីសំណាក់ប្រជាជនចិន ហើយថែមទាំងប្រៀបប្រដូចលោកជាព្រះមួយអង្គអីចឹងដែរ និងមានពិធីសែនព្រេនសុំសេចក្តីសុខពីវិញ្ញាណឡៅជឺ ទូទាំងប្រទេសឡើតផង។ ក្នុងអំឡុងសម័យកាលនោះ ព្រះដែលខ្ពង់ខ្ពស់បំផុតហើយបានទទួលការគោរពបូជាយ៉ាងខ្លាំងបំផុតពីសំណាក់ប្រជាជនចិន គឺ "ស្សៀងទី" ដែលគេមានជំនឿថា ជាព្រះបង្កើតពិភពលោកឡើង។ សូម្បីតែ "ហុងតេ" ក៏ទ្រង់នៅតែធ្វើពិធីសែនព្រេនព្រះជាម្ចាស់នៅឋានសួគ៌ជាប្រចាំឆ្នាំដែរ។ ចំណីអាហារសែនព្រេនរបស់ហុងតេ រួមមានដូចជា សាច់ជ្រូក ផ្សិត ទា មាន់ ស្រា កំណាត់ព្រៃ និងឈាមគោ ដោយមានគំនរភ្លើងទុកសម្រាប់ដុតចំណីអាហារសែនទាំងនោះ ដើម្បីឱ្យក្លិនអណ្តែតរសាត់ឡើងដល់ឋានសួគ៌ឡើតផង។ វិរបុរសដ៏អស្ចារ្យបន្ទាប់ពី ឡៅជឺ មក គឺ "ខុងជឺ" ដែលកើតមុនពុទ្ធសករាជ៨ឆ្នាំជាមនុស្សដែលមានភាពឆ្លៀវឆ្លាត និងដឹងសព្វគ្រប់នាសម័យបុរាណកាលនោះ។ នៅពេលលោកឃើញថា លទ្ធិប្រពៃណីសម័យដើម ដែលមានអាយុជាង២៥០ឆ្នាំមកហើយ លោកបានធ្វើការកែប្រែឡើងវិញខ្លះ ដើម្បីឱ្យមានសភាពប្រសើរជាងមុនរួមទាំងមានការកែប្រែដល់ប្រព័ន្ធគ្រប់គ្រងដឹកនាំប្រទេស និងរបៀបរបបការគ្រប់គ្រងប្រជាជន រហូតធ្វើឱ្យយុគសម័យនោះ កាត់បន្ថយយ៉ាងច្រើនពីការប្រព្រឹត្តបទល្មើសនៅក្នុងប្រទេសចិន។ ខុងជឺត្រូវបានគេឱ្យឈ្មោះថាជាមហាទស្សនវិទូចិនមួយរូបដ៏ល្បីល្បាញដែលមានកិត្តិស័ព្ទស្មើនឹង "សូក្រាត" នៅប្រទេសក្រិច ។

*(តទៅទំព័រទី ១២)*

# មជ្ឈមណ្ឌលអភិវឌ្ឍន៏សហគមន៏សំរាប់ ជនជាតិឯអាស៊ីភាគអគ្នេយ៏

THE SOCIO-ECONOMIC DEVELOPMENT CENTER FOR SOURTHEAST ASIANS (S.E.D.C.)

សមាជិកគណៈកម្មការមជ្ឈមណ្ឌល SEDC

**ប្រូវីដិន :** អង្គការដែលជួយ និងអប់រំកូនក្រួសារខ្មែរដ៏សំខាន់មួយនៅប្រូវីដិន គឺ SEDC។ បើតាម សំដីប្រធានមជ្ឈមណ្ឌលបច្ចុប្បន្ន អ្នកស្រី ផានីដា ភីវីលៃ (Phanida Phivilay) ជាជនជាតិលាវ ដែលបានរៀបរាប់ឱ្យដឹងថា មជ្ឈមណ្ឌលនេះ បានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៨៧ ដែលមានសមាជិកគណៈកម្មការ១៥នាក់ ហើយគណៈកម្មការទាំងនោះ គឺពុំបានទទួលប្រាក់ប្រៃវិត្យរ៍ទេតីចូលរួមបំរើការងារដោយស្ម័គ្រចិត្ត ក៏ប៉ុន្តែបច្ចុប្បន្នមានតែសមាជិក៩នាក់ប៉ុណ្ណោះដែលបំរើការងារសព្វថ្ងៃដោយមាន៦នាក់ សុំលាឈប់ ព្រោះតែពួកគាត់មានការរវល់កិច្ចការផ្ទាល់ខ្លួន។ **(តទៅទំព័រទី១៣)**

According to President of board members Ms. Phanida Phivilay, a Laotian, Socio-Economic Development Center for Southeast Asians (S.E.D.C.), this organization was formed in 1987 in Providence, Rhode Island. There are supposed to be 15 board members. Those 15 board members are serving on the board on a voluntary basis. Currently, Socio-Economic Development Center for

*(Continued to page 12)*

# យុវជនសហគមន៍ឡូវែល តាំងពិពណ៌ី "ព្យាបាលតាមរយៈសិល្បៈ"

**ខ្មែរប៉ុស្ត្ ឡូវែល** : ទ្រង់ទ្រាយច្រើនយ៉ាងនៃសិល្បៈ ដូចជា គំនូរ, សកម្មភាពសិល្បៈ, និយាយ, ចម្រៀង ឬរាំ ដោយយុវជននៅតំបន់ឡូវែល និងលីន បានត្រូវយកមកបង្ហាញសាធារណជន ក្នុងរូបភាពជាពិពណ៌ិចំរុះមួយកាល ពីថ្ងៃទី៣០-៣១ ខែមករា នៅមជ្ឈមណ្ឌល (LCHC) ។

អង្គ្រា ជា បានទៅជួបយុវសិល្បករ និងអ្នករៀបចំកម្មវិធី ទៅជួបភ្ញៀវដែលមកទស្សនាស្នាដៃយុវជនទាំងអស់គ្នាសុទ្ធសឹងសម្តែងនូវជំនឿដែលថា "សិល្បៈ គឺច្បាស់ជាវិធីដ៏សាកសិទ្ធសំរាប់ព្យាបាលជម្ងឺ ដែលនាំឱ្យមានវិបត្តិដល់សង្គម" ដូចជា វ៉ែត មូនីតា និយាយថា "សិល្បៈគឺជាកញ្ចក់ឆ្លុះបង្ហាញ ហើយព្យាបាល ហើយពិពណ៌ិយើងនេះមុខជានឹងមានទាក់ទងទៅនឹងការបាញ់របស់យុវជននៅឡូវែល កាលពីថ្ងៃទី១ ខែមករា មុននេះជាមិនខាន..." ជនី ត្រាន និយាយថា "សិល្បៈសម្រាប់ចែករំលែក ពុំមែនសម្រាប់វិនិច្ឆ័យទេ ដូចជាការបង្ហាញទស្សនៈ ពុំមានខុសឬត្រូវឡើយ" ។ យុវជនកូនភ្លោះ នីក និង ណេត បានសម្តែងថា "យុវជនត្រូវធ្វើការរួមជាមួយគ្នា ដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរ យើងត្រូវតែយកចិត្តទុកដាក់អំពីអ្វីដែលកើតឡើងក្នុងសហគមន៍..." ចំណែកឯ ទីណូ ហែម មកពីលីន បានឧទានថា "ព្រឹត្តិការណ៍ថ្ងៃនេះ គឺដើម្បីទប់ស្កាត់អំពើហិង្សា និងជួយសហគមន៍ឱ្យមានការជួបជុំគ្នា. . " ។

ឡូវែល, លីន, រីវែ ជាតំបន់នៃរដ្ឋម៉ាសាឈូសែតមានសហគមន៍ខ្មែរប្រមាណ៥ម៉ឺននាក់រស់នៅ។ សហគមន៍នេះកំពុងប្រឈមនឹងវិបត្តិហិង្សាយ៉ាងជ្រាលជ្រៅរំខានដល់ជីវភាពគ្រួសារ និងការសិក្សារបស់យុវជនយ៉ាងគួរឱ្យចាប់អារម្មណ៍ ។ ព្យាបាលដោយពិពណ៌ិសិល្បៈនេះ គឺជារូបភាពនៃការចាប់អារម្មណ៍ដ៏ត្រឹមត្រូវរបស់សហគមន៍ដើម្បីបែរមុខឆ្ពោះទៅអភិវឌ្ឍន៍បាន ។

សូមអានអត្ថបទ **អង្គ្រា ជា** ជាភាសាអង់គ្លេស :

## Lowell Youth Present: Community Healing Exhibit Through Art

*Staff Writer: Audria Chea*
*Photographer: Sam Khoeun*

On January 30th and 31st Lowell Community Health Center (LCHC) called for a "Community Healing Exhibit Through Art" in collaboration with the Lowell Youth Violence Prevention Coalition. The Exhibit featured various art forms, including displayed art of painting, drawing, printed T-Shirt, "The Line" activity, spoken words, dancing, and singing by the youths of Lowell and Lynn Massachusetts.

Monica Veth, Youth Violence Prevention Coordinator of Lowell Community Health Center stated, "This Exhibit does have a connection to the Lowell shooting of young people on January 1, 2011." On January 1, 2011 a group of young people between the ages of 14 to 20 gathered in an apartment basement (a few apartments away from where the Exhibit takes place) that lead to a dead of a 20 year-old Corrina Oeur of Lowell and injured 7 other Lowell youths. The gun men were those of a Cambodian-American male ages 19 and 20 years of Lowell as well.

*(Continued to page 09)*

PAD THAI
"ផាត់ ថៃ" មានម្ហូប ឡាវ ខ្មែរ និង ថៃ
Lao, Cambodian & Thai Food
1527 Middlesex St. #7 Lowell, MA 01851
Tel: (978) 455-3121
(behind Tae Kwon Do Plaza)
ពិសារក្នុងហាង :
• ភេសជ្ជៈអូដា និងបំពេញបន្ថែមមិនយកថ្លៃ
• មិនយកកំរែសម្រាប់កុមារអាយុតិចជាង១០ឆ្នាំ
Eat In:
Free soft drink includes refill
Free for Children Under 10 Years Old
ទិញយកចេញក្រៅ :
• ទិញម្ហូប $20 (មុនគាក់) និងបានស្លាបមាន់ក្រៅដោយឥតគិតថ្លៃ
Take Out:
Purchased with $20 (before tax) get free chicken wings
www.Padthai.foodler.com
Business Hour: Mon. - Sun. 11:00 AM to 9:00 PM
Free Delivery: Mon. - Sun. 11:00 AM to 9:00 PM

NEW
CHINA PEARL
DIM SUM
288 Mishawum Rd., Woburn, MA 01801
Phone:(781) 932-0031/Fax: (781) 932-0346
www.NewChinaPearl.com
From Boston 95 South; Exit 37B, from Lowell 93 South; Exist 37B, from RT-128; Exit 36.
ភោជនីយដ្ឋានទំនើបធំជាងគេ សូមអញ្ជើញលោកអ្នក និងក្រុមគ្រួសារមកវីតវាយជាមួយម្ហូបអាហារមកពីហុងកុង និងប្រទេសអាស៊ីនានាជុំវិញ។ យើងមានសាលកំសាន្តសំរាប់ ពិធីការ ឬកម្រីជួបជុំគ្នាមានជា និងខាងអូខេទៀតផង កន្លែងចតឡានមិនយកថ្លៃ ហើយមានសុវត្ថិភាពល្អ ។
新龍鳳大酒樓
$19.99 Per/person
Sunday Night Buffet Included :
• Lobster/Steak
Restaurant & Bar
ភោជនីយដ្ឋាន និងបា
ភោជនីយដ្ឋាន ញូ ឆាយណា កើល
Ballrooms for Wedding & Party
មានឆាកវាំសំរាប់ពិធីការ ឬប្រជុំកំសាន្ត
កាវ៉ាអូគី Karaoke
Thursday – Saturday Night
8 p.m. – 11:45 p.m.
មានឱនស៊ុមរាល់ថ្ងៃ DAILY DIM SUM
Weekdays: 11 a.m.–3 p.m.
Weekends: 10 a.m.-3 p.m.
BUSINESS HOURS: Mon - Wed 11 a.m. - 10 a.m./Thurs. & Fri. 11 a.m. - 12 Midnight / Sat. 10 a.m. - 12 Midnight / Sun. 10 a.m. - 10 p.m. Delivery Hours 11 a.m. - 9 p.m. min. $15 order plus $2 delivery.

# Best Choice

## SKIN CARE & SPA

*Tracey Ling, Manager*

930 Washington Ave. Philadelphia .PA 19147
Tel: 267.519.9908. Fax: 267.519.9913
**1.866.755.2088**

## ឯកទេសថែរក្សាស្បែក និងសុខភាព

- ជំនាញថែរក្សាផ្ទៃមុខនិងម៉ាហ្សាតាមបែបអឺរ៉ុប
- បច្ចេកវិទ្យាបញ្ចូលក្នុងស្បែកនូវអតិសុខុមនៃគ្រាប់ពេជ្រ
- សំរកទម្ងន់ និងកាត់បន្ថយខ្លាញ់ដែលលើស
- តុបតែងផាត់មុខជាអចិន្ត្រៃ
- ព្យាបាលស្បែកដែលមានពណ៌សម្បុរមិនល្អ
- ព្យាបាលមុខកើតមុន
- ព្យាបាលស្បែកដែលប្រតិកម្មដោយសារធាតុគីមី
- ធ្វើសក់ជាប្រចាំ

Eyelash Conditioner ជាផលិតផលសំរាប់ចិញ្ចឹម និងជួលសំណើមដល់រោមភ្នែកជួយឱ្យរោមភ្នែកលូតលាស់កាន់តែវែង កាន់តែក្រាស់ និងដុះលូតលាស់ច្រើនជាងមុន

Obagi Product ប៉ិនប៉ើងតាមបែបវេជ្ជ-សាស្ត្រសំរាប់ព្យាបាលទៅលើស្បែកដែលប្រែពណ៌សម្បុរស្អាមអុចខ្មៅទៅតាមវ័យស្បែក អាចមិញ និងស្អាមជ្រះវិញ្ញូ។ បណ្តុះកោសំការស្បែកមុខជាផ្ទីធ្វើឱ្យមុខមិនរលោង ក្លែងជាងវ័យ និងមានសុខភាពល្អ។



Plum Delite Plum Fruit ជាផ្ទៃព្រួចសំរកទម្ងន់ញ៉ាំមួយដងក្នុងថ្ងៃមួយ ដើម្បីឱ្យមានរូបរាងស្វែលស្អាត និងស្បែកមានសុខភាពល្អ ។

Optrimax Body Gel សំរាប់លាបលើពោះ និងរាងកាយទាំងមូល ធ្វើឱ្យពោះរៀបស្មើ និងធ្វើឱ្យរូបរាងស្រឡូនល្អ។

Beauty Body Gel ជួយបន្តឹងស្បែកឱ្យហាប់ណែនទៅត្រង់ដើមដៃ ត្រគាក ភ្លៅ និងក្បាលពោះ។

Portable Steam Sauna ប្រើប្រាស់សំរាប់គ្រួសារទទួលបានផ្ទៃរភាពកក់ក្តៅជួយធ្វើឱ្យចរន្តឈាមដើរបានល្អស្បែក បញ្ចេញចោលផ្ទៃរជាតិពុល ធ្វើឱ្យសាច់ដុំមានសភាពរឹងមាំ និងកំចាត់ចោលជាតិខ្លាញ់ដែលលើស។

Beauty Princess Cream ជាផលិតផលប្រែពណ៌មកពីប្រទេសចារ៉ង សំរាប់ធ្វើឱ្យស្បែកសនិងព្យាបាលអាចម័រុយ

All Sun Block SPF 50-88-100-108 សំរាប់លាបការពារស្បែកពីពន្លឺព្រះអាទិត្យបានយ៉ាងល្អ ដូចជានៅប្រទេសកម្ពុជា ឬស្ថិតតាមកន្លែងដែលមានពន្លឺថ្ងៃ និងមានធាតុអាកាសក្តៅខ្លាំង

Stormach Massager ម៉ាស៊ីនម៉ាស្សាពង្រាបក្បាលពោះ ធ្វើឱ្យពោះរាបស្មើ និងបាត់ណែនល្អ

Busto Lift ជាឈុតត្រែមសំរាប់លាបលើសុដន់ និងថ្នាំគ្រាប់លេបសំរាប់ពង្រីក និងធ្វើឱ្យសុដន់តឹងណែនល្អមិនធ្លាក់

កម្មវិធីពិសេសជាវិសេវាថែរក្សាស្បែកមុខ៥ដង និងថែមជូនពីរដងដោយឥតគិតថ្លៃ និងបញ្ចុះតំលៃ១៥ភាគរយ ទៅលើផលិតផលថែរក្សាស្បែកគ្រប់ប្រភេទ

ការផាត់មុខជាប្រចាំបញ្ចុះតំលៃ២០ភាគរយ

រាល់ការជាវផលិតផលស្បែកមុខ៥ដង នឹងទទួលបានការបន្ថែមមួយដងដោយ ឥតគិតថ្លៃ និងការបញ្ចុះតំលៃ១៥ភាគរយ ទៅលើការជាវផលិតផលថែរក្សា ស្បែកគ្រប់ប្រភេទ ។

# ការិយាល័យច្បាប់ មេធាវី ឡូវីស ស. ហាស្គុល

## Law Office of Louis S. Haskell

Excellent Service Since 1988

**Bankruptcy**

Save Home . Save Car . Save Job . Save Sanity

Too much credit card debt unable to pay? please let us help.

ក្ស័យធន់បែងក្រុបស៊ី:

មិនបាត់បង់ ផ្ទះ ឡាន ការងារ និងមិនឈឺក្បាល ។

ជំពាក់ក្រេឌីតច្រើន ដែលមិនអាចសងបាន សូមមេត្តាឱ្យយើងខ្ញុំជួយ ។

**សូមយកពាណិជ្ជកម្មនេះមកជាមួយ ជើម្បីពិគ្រោះដោយឥតយកកំរៃ**

ការិយាល័យយើងខ្ញុំមានការពារក្តីដោយទទួលបានជោគជ័យតាំងពីឆ្នាំ ១៩៩៨

**មានបុគ្គលិកនិយាយភាសាខ្មែរ**

16 Pine Street, Lowell, MA 01851

***Call: 978-459-8359***

### Areas of Practice: ការិយាល័យច្បាប់យើងមាន

| | |
|---|---|
| ▸ Automobile Acciden | ▸ គ្រោះថ្នាក់ចរាចរណ៏ |
| ▸ Immigration | ▸ អន្តោប្រវេសន៏ |
| ▸ Dog Bites | ▸ ឆ្កែខាំ |
| ▸ Wrongful Death | ▸ ស្លាប់ដោយសារអ្នកដទៃ |
| ▸ Fire and Burn Cases | ▸ គ្រោះថ្នាក់ភ្លើងឆេះរលាក |

# កម្មវិធីជម្ងឺទឹកនោមផ្អែមនៃប្រជាជាតិខ្មែរ-អាមេរិកាំង

## National Cambodian American Diabetes Project

Information from this booklet was adapted and made possible by the National Diabetes Education Program, a joint program of the centers for Disease Control and the National Institutes of Health (U58/CUU124586).

## លោកអ្នកអាចមើលថែរក្សាជើងរបស់អ្នកបាន!

ជម្ងឺទឹកនោមផ្អែម អាចបណ្តាលឱ្យមានបញ្ហាជាច្រើនទៀតរួមមានការខូចសរសៃប្រសាទ ស្តើកស្រពាន់ និងការកាត់ដៃ កាត់ជើង។

ការថែរក្សាជើងសំខាន់ណាស់ បើគេមានរោគទឹកនោមផ្អែម។ កូនសៀវភៅនេះជួយពីការថែរក្សាជើងរបស់អ្នក។

សូមចាប់ផ្តើមដើរហាត់ប្រាណពីពេលនោះរៀងហ្មត់ទៅ




### *You Can Take Care of Your Feet!*

Diabetes can cause many problems, including nerve damage, numbness and foot amputations. Foot-care is very important to everyone who has diabetes. This book can help you care for your feet. Get started today and walk for a lifetime!

**1** **ថែរក្សាជម្ងឺទឹកនោមផ្អែមរ**

ដោយចាក់ចងជាមួយគ្រូពេទ្យ គិលានុប្បដ្ឋាក-គិលានុប្បដ្ឋាយិកា ពេទ្យពិនិត្យជើង និង សមាគមខ្មែរផ្នែកអប់រំ សុខភាព។ សូមអោយពេទ្យពិនិត្យ ជើងរាល់ពេលដែល អ្នកជួបគេ។

**1 Take care of your diabetes.** Work with your healthcare team that includes your doctor, nurse, podiatrist and Cambodian Community Health Educator to care for your diabetes. Have your doctor check your feet at every visit!

**2** **លោកអ្នក ត្រូវពិនិត្យមើលជើងជារៀងរាល់ថ្ងៃ:**

បើលោកអ្នកពិនិត្យទៅមានបញ្ហាដូចជា :

មុតជើង ឈឺជើង ចំណុចក្រហមនៅជើង ហើម និងដំបៅក្រមុកជើង ត្រូវជំរាបដល់គ្រូពេទ្យអោយគេបានដឹងពីបញ្ហានេះ។ ចូរប្រើ កញ្ចក់ជាជំនួយ បើអ្នកឱនមិនបាន ឬពឹងគេអោយជួយ ពិនិត្យមើលជើងអ្នក។

**2 Check your feet everyday** for cuts, sores, red spots, swelling or infected nails using a hand mirror. Tell your doctor if you see any problems

**3** **សូមលាងជើងអ្នក**

ជាមួយទឹកក្តៅអ៊ុន១។ ហើយលាបប្រេងថ្នាំ ក្រមួនជើងអោយស្បែកទន់តែសូមកុំត្រាំជើង។ ចូរកុំលាបប្រេង ឬក្រមួន នៅចន្លោះម្រាមជើងអោយសោះ វាអាចបណ្តាលអោយក្លាយ ជាដំបៅ។

**3 Wash your feet** with warm water and apply lotion to your foot to keep skin soft and smooth. Avoid soaking your feet and applying lotion between the toes.

**4** **ចូរដុសខាត់ ផ្ទៃម្រាមជើង និង ស្បែកក្រិន ដោយថ្មម១**

សូមពិគ្រោះជាមួយគ្រូពេទ្យ អំពីការប្រើបពែរក្សាស្បែកក្រិន និងផ្ទៃម្រាមជើងរបស់អ្នក។ ហាមកាត់វាជាមួយឡាម ឬក៏ប្រើថ្នាំផ្សេង១ទៀត ព្រោះវាអាចធ្វើអោយមាន ដំបៅនៅលើស្បែកអ្នក។

**4 Smooth corns and calluses gently.** Avoid using corn plasters, razors or liquid removers. They can damage your skin. Talk with your doctor on how to care for calluses and corns.

**5** **ចូរកាត់ក្រចកជើង របស់អ្នកវាល់អាទិត្យ**

កុំកាត់ក្រចកជើងជ្រៅពេក។

**5 Trim your toenails each week.** Do not cut into the corners of the toenail.

**6** **ការពារជើងរបស់អ្នកវាល់ពេលវេលា**

ហាមដើរជើងទទេ នៅក្នុងផ្ទះ។ សូមពាក់ស្បែកជើងនៅផ្ទះម្យ៉ាង(ស្តើងស្រាល) បើអ្នកមិនអាចពាក់ស្បែកជើងធម្មតា ឬស្រោមជើងបាន។ ពិនិត្យមើលក្នុងស្បែកជើងរបស់អ្នក ហើយពាក់វាជាមួយស្រោមជើងដ៏ានិច្ច ក្រែងមានអ្វីក្នុងនោះធ្វើអោយ អ្នកមុត។ ការពារជើងអ្នក ឆ្ងាយពីកំដៅភ្លើង។ ហើយពាក់ស្បែកជើងនៅពេលដែលធាតុអាកាស ត្រជាក់ខ្លាំង

**6 Protect your feet at all times!** Do not walk barefoot in the house, wear slippers if you cannot wear shoe or socks in the house. Remember to wear socks with shoes and to check the insides of your shoes for sharp objects. Keep your feet away from fires and wear warm socks when it gets too cold.

**7** **ការធ្វើអោយឈាមរត់ចុះឡើងក្នុងជើងរបស់អ្នក**

ពេលអង្គុយត្រូវលើកជើងអោយខ្ពស់ ហាមអង្គុយបត់ជើង ឬខ្វែងជើងយូរពេក ហាមពាក់ស្រោមជើងណាដែលតឹងពេក។ ហាមពិសារថ្នាំ ពីព្រោះវាធ្វើអោយឈាមរត់ចុះឡើងក្នុងជើងមិនស្រួល។ ទាក់ទងជាមួយគ្រូពេទ្យ ដើម្បីត្រួតពិនិត្យ ជាតិស្ករក្នុងឈាម (A1C) សំឡេតឈាម (bloodpressure) និងខ្លាញ់ក្នុងឈាម (Cholesteral)

**7 Keep the blood flowing to your feet.** Put your feet up when you are sitting and avoid wearing tight socks. Stop smoking because it reduces your blood flow to your feet. Work with your healthcare team to control your blood sugar, blood pressure and cholesterol.

**8** **ដើរអោយបានរាល់ថ្ងៃ** ការដើរហាត់ប្រាណជួយជម្ងឺទឹកនោមផ្អែមអ្នក។ សូមពាក់ស្បែកជើង ណាដែលល្មមហើយ និងជួយពេលអ្នកដើរ។

**8 Walk Everyday!** Walking helps your diabetes. Wear athletic shoes that fit well and that will provide good support while you walk!

**A Guide for People with Diabetes**

**យោបល់ខ្លះៗសម្រាប់យើងក្នុងការជ្រើសរើស ស្បែកជើងណារំដែលល្អ ហើយតាក់ស្តួល**

- ពាក់ស្បែកជើងត្រឹមត្រូវ ជាការសំខាន់ណាស់ សំរាប់ការពារបញ្ហាធ្ងន់ធ្ងរនៃជើងរបស់អ្នក
- ស្បែកជើងហាត់ប្រាណ ឬសំរាប់ដើរល្អ សំរាប់ដើររាល់ថ្ងៃ គឺជួយទ្រទ្រង់ជើង ហើយធ្វើអោយជើងអ្នក មិនស្ទុះស្ទាប់
- សូមមិញស្បែកជើងដែលពាក់ស្រួល ហើយមិនចង្អៀតម្រាមជើង
- សូមកុំប្រើស្បែកជើងដែលស្រួចចុងជើង ឬកែងខ្ពស់ វាធ្វើអោយម្រាមជើងអ្នកប្រឹងខ្លាំង
- ផែនបណ្តាសុខភាព Medicare PartB អាចជួយចេញថ្លៃអោយអ្នកមិញ ស្បែកជើងពិសេសដែលអ្នកត្រូវប្រើ

### *Tips for Proper Footwear*

- Proper footwear is very important for preventing serious foot problems.
- Athletic or walking shoes are good for daily wear. They support your feet and allow your feet to "breathe."
- Do not wear vinyl or plastic shoes because they don't stretch or allow your feet to "breathe."
- When buying shoes, make sure they are comfortable from the start and that you have enough room for your toes.
- Do not buy shoes with pointed toes or high heels. They put too much pressure on your toes.
- Check to see if Medicare Part B will help pay for proper footwear.

# ព្រឹត្តិការណ៍អតីតចៅអធិការវត្តអង្គជុំនៅតែបន្ត

Staff Writer : Audria Chea

**ខ្មែរប៉ុស្ដិ៍, ឃុស្តុន, តិចសាស់ :** ថ្មីៗនេះតែ លោកគ្រូ ប៉ោវិន ចៅអធិការវត្តអង្គរជុំ បានហោះហើរគេចខ្លួនពីប្រព័ន្ធតុលាការទៅកម្ពុជាបាត់ទៅហើយ ហើយបានចាកសិក្ខាបទរួចទៅហើយក៏ដោយ ក៏រឿងអាស្រូវ ដែលថា ប៉ោវិន បានប្រព្រឹត្តផ្ដួរកេរខលើយុវនារីអាយុតិចជាង១៨ឆ្នាំ យ៉ាងហោចណាស់២រូបនៅពេលបុរសរូបនោះ នៅស្នៀកស្បង់ជាចៅអធិការនៅឡើយ នៅតែបន្តនៅក្នុងប្រព័ន្ធផ្សព្វផ្សាយអាមេរិកាំងនៅឡើយ។

នៅពេលដែលខ្មែរប៉ុស្ដិ៍ បានផ្សព្វផ្សាយបន្តព័តមានពី ប៉ោវិន នេះកាលពីលេខមុន លោកអ្នកជាច្រើនបានសម្ដែងការខកចិត្ត ជាពិសេសមានភាពអាម៉ាសក្នុងរូបភាពជាអ្នកកាន់ព្រះពុទ្ធសាសនា ហើយមានមតិថា "ជារឿងមិនគួរឱ្យជឿ" ឬខ្លះថា "មានតែលោកសង្ឃ១អង្គ ឬ២អង្គតែប៉ុណ្ណោះ ពុំមានរាល់ដាលទៅឆ្ងាយនោះទេ"។

មីយ៉ា សាយ បានសួរយុវនារីក្នុងរូបភាពជាអ្នករងគ្រោះ ដែលមានអាយុ១៦ឆ្នាំ និយាយថា "មានទំនាក់ទំនងជាមួយ ប៉ោវិន តាំងពីអាយុ១៥ឆ្នាំ" ប្រាប់ដល់អ្នកយកការណ៍ទូរទស្សន៍ ABC កាលពីថ្ងៃទី២៩ ខែមករា។ ទូរទស្សន៍នោះបានបញ្ចេញសម្លេងស្ត្រីម្នាក់ទៀត ដែលនិយាយថា "ប៉ោវិន បានសាកល្បងថើបកញ្ឆឹងការនាង..." មីយ៉ា បានរាយការណ៍បន្ថែមថា "នាងស្ម័គ្រចេញមុខនិយាយរឿងនេះ ដោយឃើញអ្នកនៅជុំវិញវត្តនៅតែការពារ ប៉ោវិន ជាសាធារណៈ ហើយទោះជាម្ដាយនាង ក៏មិនជឿនាងដែរ"។

អង្គ្រា ជា បានផ្ដល់វេទិកាជូនពុទ្ធសាសនិក ព្រះសង្ឃ ឬក៏គណៈសង្ឃ ដើម្បីបានជាប្រយោជន៍ក្នុងរឿងប៉ះពាល់ដល់អារម្មណ៍ខ្មែរយ៉ាងជ្រាលជ្រៅជាភាសាអង់គ្លេស :

**Monk Accused of Sexually Assaulted Underage Girl Now Determent "Defendant"**

Houston Texas' media continue the on-going coverage on the first Buddhist monk case in the U.S, accused of sexually assaulting the underage girl repeatedly. The allegations happened in December 2010 when the 16 year-old alleged victim confined to school's youth services specialist that she was having sex with a monk during her visits to the temple with her mother.

The investigator from Harris County Sheriff's Crime Against Children Division began the interview with the alleged victim on December 10, 2010. Sergeant William Lilly from the Crime Against Children Division confirmed that based on the alleged victim's disclosures, enough information was collected to serve as probable cause for charges against Por Venh.

Houston Chronicle reported monk Por Venh 41, accused of sexually assaulting the 16 year-old girl from June to September, 2010. Two charges already been filed against this monk on January 14. Due to "typographical" error the indictments were dismissed four days later, but re-filled again on January 19, per spokeswoman Donna Hawkins from the District Attorney's Office. Por Venh also had been ordered held on bonds totaling $40,000, at $20,000 on each charged. His attorney reported the alleged monk fled his monastery in Spring Texas to Cambodia on January 4. According to prosecutors the monk fled to avoid facing charges of sexually assaulting the 16 year-old girl.

On January 29 ABC 13 Eyeswitness News reporter Miya Shay spoke with the 16 year-old alleged victim who said it all began when she was 15, accompanying her mother to the temple which her mother cook and clean. In the interviewed the girl stated, "I know what he was doing to me, and I guess I feel upset." She recalled the 41 Por Venh touched her chest. Per court documents, the alleged victim also reported in December 2010 that the sexual relations between her and the monk took place in his living quarters of the Temple. Another girl who spoke with Shay over the phone reported the same monk tried to kiss her on the neck. Prosecutors believed there might be more girls victimized by Por Venh.

The alleged victim told ABC 13 Eyeswitness News she wanted to speak out after watching other members of the temple defend the monk in public. She also commented that her own parents don't believe her.

**Cambodian American Community's take on the issue:**

Asking not to be identified an American born Cambodian Reverian comment, "like the court say....no one is yet assume guilty, until otherwise proven guilty." She said she learned this line from a "Court TV" show. She continues, "But if the alleged victim turns out to be a real victim, I say power to her for the courage to speak the truth...and put the predator under the punishment of the rightful law."

A Cambodian woman from Alexandria Alabama who reacted with dismay to the news at first then stated, "There could be a monk like this. If the truth is being barricaded there will be no real solution coming out from what happened, therefore no specific punishment can be draw from the Buddhist Monk Association rules." She also continued, "Monks who are selected to serve in the U.S. Buddhist Temple from Cambodia usually is well respected by the respectable level of his education, specifically education in religious virtues, Buddhist monk virtuess, and Dharma virtues. If the accused monk is innocent he shouldn't have run away. *(Continued to page 08)*


# ភោជនីយដ្ឋាន ណាម វាង (ភ្នំពេញ)
*Nam Vang Restaurant*

**571 Unit#1 Adams Svenue. Philadelphia, PA 19120**
**(inside Hong Kong Market) (215) 742-9488**

ប្រែរាល់ថ្ងៃលោកអ្នកអាចពិសាចំណីគ្រឿងឆ្ងាញ់ គ្រប់សេជាតិផ្លែឈើ ដូចជា: ទុរេន ឬ អាវ៉ាកាដូ ហើយជាពិសេសមានចំណីគ្រឿងស្រស់ៗ

**១_មុខជំនាញខាងម្ហូបខ្មែរ យ៉ាងចំណាន ដូចជា :**
-គុយទាវភ្នំពេញ
-គុយទាវ ឬមី-ខតោ
-មីកន្ដ្រាំង ឆាសាច់គោ
-មីកន្ដ្រាំងឆាគ្រឿងសមុទ្រ
-បាយឆាគ្រប់មុខ
-សាច់គោអាំង ចង្កាក់ ជាមួយជ្រក់ល្ហុង

**២_មុខជំនាញម្ហូបផ្សែតណាម ល្បីឈ្មោះ ដូចជា :**
-ទំបញ្ចកទឹកត្រីពិសេស
-ទំប៉ុងជាតេ ឬសាច់គោអាំង
-ខតោ ទំប៉ុង ឬ មី និងគុយទាវ
-បាយសរសាច់ជ្រូកអាំង ឬសាច់មាន់អាំង

**Open 7 days a week from 9a.m-9p.m**
**បើក 7 ថ្ងៃក្នុងមួយអាទិត្យពីម៉ោង 9-ព្រឹក-ដល់-9-ល្ងាច**

# ក្រុមហ៊ុន ឧទសចរណ៍
## CENTURY TRAVEL & SERVICE CENTER

**904 South 8th Street. Philadelphia, PA 19147**
**Tel : 215-625-2889; Fax : 215-625-9395**
**Cell : 267-934-9888; Email : centuryphl@yahoo.com**

- បំរើលោកអ្នកដោយគ្រប់ក្រុមហ៊ុនអាកាសចរណ៍ សំរាប់ដំណើរហើរក្នុងនិងក្រៅស្រុក
- ជួយរកអ្នកនាំផ្លូវជូនដំណើរទស្សនកិច្ចធ្វើការ
- ពន្យាលិខិតឆ្លងដែនខ្មែរ
- ធ្វើលិខិតអន្តោប្រវេសន៍
- ផ្ញើប្រាក់ប្រចាប់ត្រាបញ្ជាក់លើលិខិតជាផ្លូវការ

- Serve all Airlines
- Domestic & Intl. flights
- Tour Arrangements
- Passport Extension
- Khmer Laissez- Passer
- Immigration
- Tourist Visa
- Notary Public

**OFFICE Hours :**
**Mon - Sat 10:00 A.M - 6:00 P.M**
**Sun : 12:00 P.M - 5:00 P.M**

We Speak Khmer, Chinese, Vietnamese
យើងនិយាយភាសាខ្មែរ-ភាសាចិន-វៀតណាម

# កិច្ចសម្ភាសន៍ឯកឧត្តម សមរង្ស៊ី ជាមួយនឹងវិទ្យុចាំងអន្តរជាតិ កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១

**លោកអ្នកអានចង់ដឹងថា សម រង្ស៊ី កំពុងរស់នៅក្រៅប្រទេស តើគណបក្សប្រឆាំងចំជាងគេនៅកម្ពុជានេះ មានដំណើរការយ៉ាងណាទៅហើយ? លោក សម រង្ស៊ី ពីប្រទេសបារាំងឆ្លើយនឹងចម្ងល់នេះដូចតទៅ :**

**សំនួរ :** ជំរាបសួរគណកម្មាធិការអចិន្ត្រៃគណបក្សសមរង្ស៊ី បានបើកកិច្ចប្រជុំរបស់ខ្លួនពីថ្ងៃទី១៦ ដល់ថ្ងៃទី២៤ ខែមករា នៅក្នុងទីក្រុងម៉ានីល ប្រទេសហ្វីលីពីន។ ខ្ញុំបាទចង់ដឹងថា តើមានប្រធានរឿងអ្វីខ្លះដែលកិច្ចប្រជុំបានលើកយកទៅជជែកនិងបានសំរេច?

**ចំលើយ :** ប្រធានបទគឺការវាយតំលៃអំពីស្ថានការណ៍ការវិវត្តន៍ស្ថានការណ៍ យើងបានយល់ច្បាស់លាស់អំពីស្ថានការណ៍ដូច្នេះយើងត្រូវតែកំណត់ ឬបញ្ជាក់អំពីយុទ្ធសាស្ត្ររបស់យើង ហើយការអភិវឌ្ឍន៍យុទ្ធសាស្ត្រនេះតំរូវឱ្យមានការរៀបចំគណបក្ស សមរង្ស៊ី ឱ្យកាន់តែខ្លាំងឡើងថែមទៀត ។

**សំនួរ :** តើយុទ្ធសាស្ត្រហ្នឹង មានអ្វីខ្លះទៅ?

**ចំលើយ :** យុទ្ធសាស្ត្រគឺការផ្តល់សន្ទុះថ្មីឱ្យគណបក្សសមរង្ស៊ី ព្រោះគណបក្ស សមរង្ស៊ី ត្រូវតែតាំទ្រប្រជាពលរដ្ឋខ្មែរដែលរងគ្រោះកាន់តែច្រើនឡើង។ ដែលមានការឈឺចាប់ហើយទាមទារឱ្យមានការផ្លាស់ប្តូរនៅប្រទេសកម្ពុជា ។

**សំនួរ :** ជាយុទ្ធសាស្ត្រក្នុងការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១២ និងតំណាងរាស្ត្រថ្មីនៅឆ្នាំ២០១៣? ។

**ចំលើយ :** បាទ ប៉ុន្តែមានកិច្ចការដែលយើងត្រូវតែធ្វើជាបន្តបន្ទាប់ចាប់ពីថ្ងៃនេះទៅរហូតដល់ថ្ងៃបោះឆ្នោតយើងមិនចាំដល់ថ្ងៃបោះឆ្នោតទេ ។

**សំនួរ :** មានរឿងស្រពេចស្រពិលមួយនៅផ្ទៃក្នុងគណបក្ស សមរង្ស៊ី នោះគឺការផ្លាស់ប្តូរតំណាងរាស្ត្រមួយចំនួននៅពាក់កណ្តាលអាណត្តិស្របតាមសេចក្តីសំរេចនៃកិច្ចប្រជុំគណកម្មាធិការអចិន្ត្រៃគណបក្សកាលពីថ្ងៃទី៥ ដល់ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៨ នៅក្នុងសន្និសីទកាសែតនាថ្ងៃទី២៥ ខែមករា ឆ្នាំ២០១១នេះ លោក ឃឹម សុវណ្ណ អ្នកនាំពាក្យគណបក្ស សមរង្ស៊ី បានបញ្ជាក់ដោយស្មាក់ស្មើរចំពោះបញ្ហានេះ។ ឥឡូវខ្ញុំចង់បានចម្លើយពីឯកឧត្តម តើមាន ឬមិនមានការផ្លាស់ប្តូរតំណាងរាស្ត្រខ្លះរបស់គណបក្ស សមរង្ស៊ី បើមាន មានក្នុងមណ្ឌលណាខ្លះ? បើអត់ដោយសារមូលហេតុអ្វី?

**ចំលើយ :** នេះស្ថិតក្នុងការរៀបចំគណបក្សសមរង្ស៊ីក្នុងទ្រង់ទ្រាយធំមិនត្រឹមតែការផ្លាស់ប្តូរអ្នកតំណាងរាស្ត្រគ្រាន់តែការឆ្លាស់តំណែងគ្នានោះទេ គឺការរៀបចំគណៈបក្សសមរង្ស៊ី នេះគឺតំរូវឱ្យមានការឆ្លាស់ប្រធានក្រុមប្រឹក្សាខេត្ត គឺមេបក្សខេត្តគណបក្ស សមរង្ស៊ី ត្រប់ខេត្តទាំងអស់ដែលបានកាន់តំណែងលើសពីពីរអាណត្តិ។ ក្នុងបក្សគឺប្រាំមួយឆ្នាំ ត្រូវតែមានការផ្លាស់ប្តូរត្រូវតែមានអ្នកថ្មីមកជំនួស ហើយក៏មានការឆ្លាស់គ្នាផ្លាស់ប្រធានខេត្តមួយទៅកាន់ខេត្តមួយទៀត អ្នកដែលឈរជាតំណាងរាស្ត្រអ្នកដែលឈរជាបេក្ខជន គឺយើងត្រូវតែគិតគូរតាមហ្នឹងដែរ ។

**សំនួរ :** ការផ្លាស់ប្តូរនឹងអាចមាននៅពេលណា?

**ចំលើយ :** គឺមានហើយចាប់តាំងពីយើងបានប្រជុំនៅទីក្រុងម៉ានីល ពីរសប្តាហ៍មុនហើយសេចក្តីសំរេចនោះគឺយើងយកមកអនុវត្តភ្លាម ។

**សំនួរ :** តាមធម្មតាតំណាងរាស្ត្រពាក់កណ្តាលអាណត្តិរបស់គណបក្ស សមរង្ស៊ី ត្រូវដល់កំណត់នៅថ្ងៃទី២៤ ខែមិនាខាងមុខ។ ឯកឧត្តមតើជំរើសនៃការរុសរើតំណាងរាស្ត្រពាក់កណ្តាលអាណត្តិជាជំរើសមួយដើម្បីកុំឱ្យមានការច្រណែនគ្នាឬមួយក៏មានគោលដៅអ្វីផ្សេង?

**ចំលើយ :** គោលការណ៍គឺតំណាងរាស្ត្រណា មេបក្សខេត្តណាក៏ដោយដែលទទួលខុសត្រូវជាទូទៅបើចង់ឱ្យមានតម្លាភាពគឺត្រូវតែផ្លាស់ពីកន្លែងមួយទៅកន្លែងមួយ ហើយជាគោលការណ៍គឺយើងផ្តល់តួនាទីឱ្យអ្នកដែលស្មោះត្រង់ជាមួយជាតិ និងគណបក្សឱ្យមានតួនាទីសមស្រប ទោះជាមិនធ្វើតំណាងរាស្ត្រពេញអាណត្តិក៏អាចធ្វើតំណាងរាស្ត្រមួយរយៈពេល ឬក៏អាចធ្វើជាព្រឹទ្ធសភា ហើយអ្នកស្មោះត្រង់មួយចំនួនក៏បានក្លាយជាសមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត និងក្រុម សូមជំរាបថាគណបក្ស សមរង្ស៊ី មានសមាជិក សមាជិកាដែលបានជាប់ឆ្នោតក្នុងក្របខណ្ឌរដ្ឋជាងបីពាន់នាក់ គឺបីពាន់បីរយអ្នកដែលយើងបានជ្រើតចូលក្នុងរចនាសម្ព័ន្ធរបស់រដ្ឋគ្រប់ជាន់ថ្នាក់ ។

**សំនួរ :** ខ្ញុំសូមអនុញ្ញាតត្រឡប់មកចាប់អារម្មណ៍អំពីសម្ព័ន្ធភាពគណបក្ស សមរង្ស៊ី និងគណបក្សសិទ្ធិមនុស្សរបស់លោក កឹម សុខា។ ក្នុងលិខិតផ្ញើជូនឯកឧត្តមចុះថ្ងៃទី២៥ ខែមករា លោក កឹម សុខា បានជំរុញឱ្យឯកឧត្តមបន្តជជែកពីការបង្រួបបង្រួមក្នុងនាមសម្ព័ន្ធភាពគណបក្សប្រឆាំង ដែលកំពុងជាប់គាំងជាងពីរឆ្នាំមកហើយ ត្រង់ចំណុចនេះគណបក្សសិទ្ធិមនុស្សមិនញញើតនឹងចោទគណបក្ស សមរង្ស៊ី ថាជាអ្នកយកជើងរាទឹក។ ក្នុងលិខិតរបស់ឯកឧត្តមផ្ញើជូនលោកកឹម សុខាចុះថ្ងៃទី២៤ មករា ពីប្រទេសហ្វីលីពីន ពោលគឺ១ថ្ងៃមុនលិខិតរបស់លោក កឹម សុខា ឯកឧត្តមបានដាក់សំណើរពីរទៅលោក កឹម សុខា ដែលក្នុងនោះមានសំណើរមួយដែលចែងថា រក្សាឈ្មោះគណបក្ស សម រង្ស៊ី ជាគណបក្សរួមហេតុអី ?

**ចំលើយ :** អ្វីដែលយើងធ្វើគឺយើងត្រូវតែរក្សាស្ថេរភាពចលនាប្រជាធិបតេយ្យ ព្រោះយើងឃើញពីអតីតកាលដូចជាគណបក្សលោកតាសឺនសាន បានប្តូរឈ្មោះដោយគេលួចបន្លំគេបំបែកឈ្មោះគណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនានោះ ទើបសម្តេចសឺនសាន បានសំរេចចិត្តបង្កើតឈ្មោះគណបក្ស

(មានតទៅលេខក្រោយ)


ពេលវេលា និងម៉ោងផ្សាយកម្មវិធីជាភាសាខ្មែរ

តាមរយៈស្ថានីយ៍ទូរទស្សន៍ប៊ុស្តីលេខ ៨ ក្រុងឡូវែល រដ្ឋម៉ាសាឈូសេត

| ថ្ងៃ Date | ឈ្មោះកម្មវិធី Program | ម៉ោង Time | រយៈពេល Duration |
|---|---|---|---|
| ថ្ងៃច័ន្ទ Monday | ប្រពៃណីខ្មែរ | 12:00 PM | 01:00:00 |
| | សម្លេងខ្មែរ-អាមេរិកាំង | 08:00 PM | 01:00:00 |
| | ជីវិតថ្មី Jivit Thmei | 09:00 PM | 01:00:00 |
| ថ្ងៃអង្គារ Tuesday | ខ្មែរក្រុងឡូវែល | 12:00 PM | 01:00:00 |
| | ខ្មែរភៀសខ្លួន Khmer Refugee | 06:00 PM | 01:00:00 |
| | ជីវិត និង សិល្បៈ Life and Arts | 07:00 PM | 00:30:00 |
| ថ្ងៃពុធ Wednesday | សមាគមខ្មែរ CMAA TV Show | 07:00 PM | 01:00:00 |
| | មនោសញ្ចេតនាខ្មែរ | 08:00 PM | 01:00:00 |
| ថ្ងៃព្រហស្បត្តិ៍ Thursday | បុណ្យអុំទូក | 07:00 PM | 01:00:00 |
| | នាទីសង្គមខ្មែរ | 08:00 PM | 01:00:00 |
| ថ្ងៃសុក្រ Friday | ព្រះពុទ្ធសាសនាខ្មែរ | 12:00 PM | 01:00:00 |
| | Khmer Charisma Live | 05:00 PM | 01:00:00 |
| | ព័ត៌មានវត្ត Temple News | 08:00 PM | 01:00:00 |
| ថ្ងៃសៅរ៍ Saturday | Cambodian Baptist | 03:00 PM | 01:00:00 |
| ថ្ងៃអាទិត្យ Sunday | ដំណើរទៅស្រុកខ្មែរ | 06:00 PM | 01:00:00 |

ពេលវេលា និងម៉ោង ផ្សាយកម្មវិធីជាភាសាខ្មែរ

តាមរយៈស្ថានីយ៍ទូរទស្សន៍ប៊ុស្តីលេខ ៩៥ ក្រុងឡូវែល រដ្ឋម៉ាសាឈូសេត

| ថ្ងៃ Date | ឈ្មោះកម្មវិធី Program | ម៉ោង Time | រយៈពេល Duration |
|---|---|---|---|
| ថ្ងៃច័ន្ទ Monday | Cambodian Baptist | 09:00 AM | 01:00:00 |
| | ខ្មែរភៀសខ្លួន Khmer Refugee | 07:00 PM | 01:00:00 |
| ថ្ងៃអង្គារ Tuesday | ប្រពៃណីខ្មែរ Khmer Tradition | 12:00 PM | 01:00:00 |
| | Khmer Charisma | 03:00 PM | 01:00:00 |
| ថ្ងៃព្រហស្បត្តិ៍ Thursday | ព័ត៌មានវត្ត Temple News | 08:00 PM | 01:00:00 |
| ថ្ងៃសុក្រ Friday | ដំណើរទៅស្រុកខ្មែរ | 02:00 PM | 01:00:00 |
| | ជីវិតថ្មី Jivit Thmei | 07:00 PM | 01:00:00 |
| | មនោសញ្ចេតនាខ្មែរ | 08:00 PM | 01:00:00 |
| ថ្ងៃសៅរ៍ Saturday | ព្រះពុទ្ធសាសនាខ្មែរ | 03:00 PM | 01:00:00 |
| | ខ្មែរក្រុងឡូវែល Khmer Lowell | 04:00 PM | 01:00:00 |
| ថ្ងៃអាទិត្យ Sunday | នាទីសង្គមខ្មែរ Khmer Talk | 12:00 PM | 01:00:00 |
| | សមាគមខ្មែរ CMAA TV Show | 01:00 PM | 01:00:00 |
| | បុណ្យអុំទូក | 05:00 PM | 01:00:00 |
| | ជីវិត និងសិល្បៈ Life and Arts | 06:00 PM | 00:30:00 |
| | សម្លេងខ្មែរ-អាមេរិកាំង | 07:00 PM | 01:00:00 |

ពេលវេលា និងម៉ោងផ្សាយកម្មវិធីជាភាសាខ្មែរ

តាមរយៈវិទ្យុ **WUML - 91.5 FM** ក្រុងឡូវែល រដ្ឋម៉ាស្សាឈូសេត

| | |
|---|---|
| វិទ្យុសំឡេងកុលបុត្រខ្មែរ Voice of Cambodian Children | វិទ្យុសំឡេងសមាគមខ្មែរ Voice of CMAA-Thinking Out Loud Radio |
| ផ្សាយរាល់ថ្ងៃអាទិត្យ ម៉ោង១រសៀល ដល់ម៉ោង៥ល្ងាច | ផ្សាយរាល់ថ្ងៃសុក្រ ម៉ោង១១ព្រឹក ដល់ម៉ោង១២ថ្ងៃត្រង់ |

# The Power To Make Social Change = MKL

នេះជាសេចក្តីរាយការណ៍ភាគពីរស្តីពី "ទិវា ម៉ាតាំង លូទ័រឃីង" រាយការដោយ ភាសាអង់គ្លេសដោយ **ជាណាលី សែម** ដែលបានតាមដាន និងសម្ភាសន៍បាតុករ ដែលខឹងសម្បារនឹងឃើញរដ្ឋាភិបាល សហរដ្ឋអាមេរិកបន្តប្រើច្បាប់និរទេសខ្លួនអតីតពិរុទ្ធជន ឱ្យទៅប្រទេសដើមកំណើររបស់ខ្លួន ដោយពុំមានឱ្យ តម្លៃទៅលើការខិតខំកសាងខ្លួនឱ្យបានជាមនុស្សល្អ ប្រសើរឡើងវិញ មានគ្រួសារមានការងារច្រើនឆ្នាំទៅ ហើយក៏ដោយក្តី។

នាថ្ងៃដង្ហែរក្បួនបាតុកម្មដ៏ធំ គឺថ្ងៃទី១៧ ខែមករា ដែលមានសមាជិកភាគច្រើនសុទ្ធតែខ្មែរនោះ **មាលា** ជា អ្នករៀបចំដង្ហែរក្បួនពីសហគមន៍ខ្មែរ បាននិយាយប្រាប់ **ជាណាលី** ថា "ថ្ងៃទី២១ ខែកញ្ញា សមាជិកសហគមន៍ ខ្មែរ៨រូបត្រូវប៉ូលីសចាប់ខ្លួនដាក់គុកដើម្បីរង់ចាំការ និទេសទៅកម្ពុជាវិញ... ហើយយើងមកជួបជុំគ្នានេះ ដើម្បីសម្តែងការពិតមួយ ថាគេពុំអាចឃុំមនុស្សដោយ ពុំមានហេតុបានតទៅទៀតទេ ជាពិសេសនៅពេលដែល ក្រុមគ្រួសារត្រូវការពួកគេនៅក្នុងសហគមន៍"។

នាពេលនោះបេក្ខជន គណៈក្រុមប្រឹក្សាក្រុងហ្វីឡា ដែលហ្សៀ អន់ឌឺ ថយ បាននិយាយថា "ខ្ញុំគិតថាយើង ត្រូវការឱ្យមានលទ្ធភាពដើម្បីពិនិត្យករណីម្តងមួយៗជា ចាំបាច់..." ។

បាតុករប្រមាណ១000នាក់ឃើញថា ស្មារតីរបស់ បណ្ឌិត ឃីង មានជោគជ័យលើវិស័យច្រើនហើយ តែ មិនទាន់គ្រប់គ្រាន់នៅឡើយទេ..." ។ **-ខ្មែរប៉ុស្តិ៍-**

Dannaly Sam
The Khmer Post

PHILADELPHIA, PA- Martin Luther King, Jr. Day was the backdrop for protestors and organizers of one of various nonviolent movements held to draw attention upon the recently incarcerated and to be deported members of the Cambodian community.

Mia-Lia Kiernan, one of the organizers of the movement says, "On September 21st, four members of the Cambodian community were detained at the building for deportation to Cambodia, and so we're coming here today…to try to bring more awareness about the fact that they can't just hold people for no reason, especially when their families need them here in this community."

The rally began soon after the performances and speeches that were given in celebration of the legacy and triumph of Martin Luther King, Jr.'s efforts for change and justice through nonviolence. A wide age range of the old to the young participated in the rally. Babies sat wrapped in their strollers, while their parents pushed them, and the elderly walked side by side with the young from the Arch Street United Methodist Church on Broad Street to the

Philadelphia branch of the United States Immigration and Customs Enforcement (ICE) on 16th and Callowhill Streets.

The rally was highlighted by the messages on the yellow ribbons written in an effort to voice to the ICE officials their calling to action. Some ribbons were worn by rally participants, but many were tied to the gates across the street from the ICE building.

Support from the crowd was given to Desi Burnette's words, saying, "These deportations will not bring back our security or prosperity. They will not make our schools better, or create jobs."

A division of the United States Department of Homeland Security, the ICE stated on their website that the Enforcement and Removal Operations of ICE "…identifies and apprehends removable aliens, detains these individuals when necessary and removes illegal aliens from the U.S. This unit prioritizes the apprehension, arrest and removal of convicted criminals, those who pose a threat to national security, fugitives and recent border entrants."

Andy Toy, a Democratic candidate for the Philadelphia City Council said, "Right now it's as if it's an automatic deportation, or it's an automatic allowance to deport people even after they've gotten themselves back on track, and they have families, and they're good upstanding citizens, for something that they did maybe twenty years ago…I think that we need to have some way to look at each case individually."




Four of the members of the Cambodian community are to be deported and are currently detained include Chally Dang, Mout Iv, Davy Pieng, and Vanny Van. Each person was a legal resident in the U.S. has committed a crime when they were younger, went to U.S. prisons for these crimes, and were released until the immigration officials detained them years later.

The deportation and immigration laws can be traced back to 1996 during the Clinton Administration. It was stated that any non-citizen civilians in the U.S. who has committed a crime or misdemeanor can be deported to their home country, if the country they are a citizen of accepts deported persons. The Cambodian government signed an agreement in 2002 acknowledging the deportation of Cambodian refugees in the U.S.

Kiernan says there is no word whether Chally Dang will be deported or released from the York County Prison, the ICE detention center he is detained at, as of this moment.


## KhmerPost LLC
## East Coast Publication

**Pin Samkhon,**
*Publisher & Editor-in-Chief*
Email: pinsamkhon@gmail.com
*Staff Writers:* **Loeum Im,**
**Eda Uong, Audria Chea, Sovan Heng**

*Contributed Writers:*
**Mam Yin, Kim Phien,**
**Lanica Angpak, & Dannely Sam**
KhmerPostLowell@gmail.com

**Soben Pin**
*Marketing Director*
KhmerPostUSA@gmail.com
**267-253-3947**
**Sam Khoeun**
*Sales Consultant*
**(781) 244-0522**

*Design Staffs:*
**Leang Heng & Doch Vuthy**
*Distributor:* ***Chharly Young***

~~~~

KhmerPost LLC is an independent newspaper that aims to facilitate mass communication among the Cambodian communities, their neighboring communities, and families. We aim to address local, community, and national news; and give an insight into Cambodia & global news. We also strive to bridge the language and cultural gaps and reduce social isolation by publishing in Khmer & English.
It published twice a month in Pennsylvanian & Massachusett.

~~~~

Semimonthly edition subscription is available within the U.S. & Canada at $60.00 and 70 Euros in Europe per year. Money order or check is accepted and made payable to:
U.A.M.G.
P.O. Box 24357
Philadelphia, Pa 19120

~~~

The Khmer Post has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009



# ART OF WELLNESS CENTER

Art of Wellness
"Integrating Holistic Healthcare for the Mind, Body, and Spirit."
(215)305-2238
www.artofwellnesscenter.com

មន្ទីរសុខភាព *"Art Wellness"* ទទួលព្យាបាលបញ្ហាផ្លូវចិត្ត និងថ្នើមៅតាម
ទម្លាប់ និងជំងឺរបស់លោកអ្នក ដោយប្រើរបៀបបច្ចេកទេសអាស៊ី និងបច្ចេកវិទ្យាបស្ចឹមប្រទេស ។

**ចំពោះលោកអ្នកមានការចង់ចាកណាមួយដូចចំណុចខាងក្រោម :**

- ធ្លាក់ទឹកចិត្ត DEPRESSION
- ការថប់អារម្មណ៍ ANXIETY
- ភាពតានតឹង STRESS
- មានកំហឹងច្រើន ANGER MANAGEMENT
- ឈឺខ្លួនប្រាណគ្រប់កន្លែង PAIN MANAGEMENT
- មានវិបត្តិក្នុងគ្រួសារ FAMILY ISSUES
- ការញៀន និងអ្វីមួយ ADDICTION ISSUES
- សុខភាពស្ត្រី WOMEN'S HEALTH

- Allergy Testing & Elimination
- Weight Managerment for Adult & Children
- Diabetes
- High Blood Pressure
- High Cholesterol Level Issue
- ការប្រតិកម្មនឹងធាតុអ្វីមួយ ហើយបំបាត់វាចេញ
- គ្រប់គ្រងទម្ងន់សម្រាប់ចាស់និងក្មេង
- ទឹកនោមផ្អែម
- លើសសម្ពាធឈាម
- លើសកាឥត កូលេស្តេរ៉ុល
- Insomnia (Difficulty Sleeping)
- Facial Acupuncture (reduce wrinkles)
- Nutrition Consultation (Free)
- Genetic Testing
- Feeling Tired & Weak
- We Accept AETNA & United Healthcare
- ដេកមិនលក់
- ប្រើមូលព្យាបាលលើផ្ទៃមុខ ( បន្ថយភាពជ្រីវជ្រួញ)
- ពិគ្រោះពីម្ហូបអាហារ ( មិនយកកាំបិ)
- ធ្វើតេស្តអំពីពូជ
- អស់កម្លាំង មិនស្រួលខ្លួន
- យើងទទួលយក AETNAនិង UNITED HEALTHCARE

## ទទួលព្យាបាលគ្រប់វិស័យ

| ទទួលព្យាបាលគ្រប់វិធី | TREATMENT TYPE |
|---|---|
| • ប្រើម្ជុលឥតថ្នាំ | • Acupuncture |
| • ចាប់សរសៃ | • Acupressure |
| • ចិត្តវិទ្យា | • Psychotherapy |
| • យោគៈ/ភាវនា | • Yoga/ Meditation |

វេជ្ជបណ្ឌិតនឹងអ្នកជំនាញការមានបទពិសោធន៍
ច្រើនឆ្នាំនៅប្រទេសចិន និងនៅសហរដ្ឋអាមេរិក ។
សូមអញ្ជើញទូរស័ព្ទ ឬមកមន្ទីរពេទ្យសុខភាព
យើងខ្ញុំ ដើម្បីពិគ្រោះវិធីព្យាបាល

ART OF WELLNESS CENTER
647 BAINBRIDGE STREET,
PHILADELPHIA, PA 19147
**215-305-2238**
ភាសាខ្មែរទាក់ទង ប៊ុន រ៉ាត់ : **267-242-8526**
~~~

ឌី ឃែមបូឌា ដេលី The Cambodia Daily

ដំណឹងច្រៃសំរួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌី ឃែមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃសុក្រ ទី០៤ ខែកុម្ភៈ ឆ្នាំ២០១១

# Thai Officials Arrive in Cambodia Following Espionage Convictions

By Neou Vannarin
THE CAMBODIA DAILY

While Thai Foreign Affairs Minister Kasit Piromya touched down in Siem Reap City yesterday for talks with his Cambodian counterpart, Thailand's deputy prime minister flew straight to Phnom Penh to meet with Prime Minister Hun Sen.

The sudden high-level diplomacy follows Tuesday's espionage convictions of Thai "yellow shirt" Veera Somkwamkid and his assistant. In a ruling criticized by the Bangkok, the pair was sentenced to eight and six years in jail, respectively.

The Cambodian military has meanwhile been building up its troop and artillery numbers in Preah Vihear province along a 4.6-square-km stretch of border claimed by both Cambodia and Thailand. Though RCAF officials say the buildup is a response to similar moves from Thailand, Thai officials have not confirmed the reports.

The Bangkok Post reported yesterday that Thai Deputy Prime Minister Suthep Thaugsuban and National Security Council Secretary-General Thawil Pliensri made an "urgent" trip to Phnom Penh yesterday to discuss the countries' "strained relations."

Council of Ministers spokesman Phay Siphan said he had no details about what was discussed.

Foreign Affairs spokesman Koy Kuong said he did not know of Mr Suthep's arrival, but confirmed that Mr Kasit would attend the latest meeting of the Joint Commission for Bilateral Relations Between Cambodia and Thailand, adding that Mr Kasit and Foreign Affairs Minister Hor Namhong would discuss "all sectors between Cambodia and Thailand."

Some 40 Thai officials were already in Siem Reap for the first day of the meeting yesterday.

Thai Foreign Affairs spokesman Thani Thongphakdi could not be reached yesterday. On Wednesday, he said Mr Veera's conviction was not on the meeting's agenda but could come up.

Pech Vicheka, one of the pair's lawyers, said he would file an appeal sometime next week.

In Bangkok, Thai nationalist groups have threatened a mass street rally aimed at toppling the government if it failed to secure their release by Saturday.

# ក្រុមមន្ត្រីថៃមកដល់កម្ពុជាក្រោយពីមានការផ្តន្ទាទោសពីបទចោរកម្ម

ដោយ ខៅ វណ្ណារិន
THE CAMBODIA DAILY

ខណៈដែលលោក កាស៊ីត ភិរម្យ ជាមន្ត្រីការបរទេសថៃបានមកដល់ក្រុងសៀមរាមកាលពីម្សិលមិញ សម្រាប់ការពិភាក្សាជាមួយសមភាគីកម្ពុជារបស់លោកនោះឧបនាយករដ្ឋមន្ត្រីនៃប្រទេសថៃបានជិះយន្តហោះឆ្ពោះត្រង់មកកាន់ក្រុងភ្នំពេញតែម្តង ដើម្បីជួបជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុនសែន ដោយផ្ទាល់។

សកម្មភាពភ្លាម១ផ្នែកការទូតកម្រិតខ្ពស់នេះ កើតមានក្រោយតុលាការក្រុងភ្នំពេញផ្តន្ទាទោសកាលពីថ្ងៃអង្គារ លើ "ក្រុមអាវលឿង" របស់ថៃ គឺលោក វីរ៉ា សុមខ្វាមឃីត និងជំនួយការរបស់គាត់ពីបទចារកម្ម។ នៅក្នុងសេចក្តីសម្រេចមួយដែលត្រូវបានរដ្ឋាភិបាលថៃរិះគន់នោះ តុលាការបានកាត់ទោសជនទាំងពីរនេះឱ្យជាប់ពន្ធនាគារម្នាក់៨ឆ្នាំនិងម្នាក់ទៀត៦ឆ្នាំ។

ទន្ទឹមនឹងនេះដែរ យោធាកម្ពុជាបាននិងកំពុងបង្កើតចំនួនកងទ័ព និងកាំភ្លើងធំរបស់ខ្លួននៅក្នុងខេត្តព្រះវិហារតាមបណ្តោយតំបន់ព្រំដែនចំហ៤.៦ គីឡូម៉ែត្រការដែលទាំងកម្ពុជាទាំងថៃសុទ្ធតែបានអះអាងថាជារបស់ខ្លួន។ បើទោះជាក្រុមមន្ត្រី យោធពលខេមរភូមិន្ទនិយាយថាការបង្កើនចំនួនទ័ពនិងកាំភ្លើងធំនេះគឺជាការឆ្លើយតបទៅនឹងចំណាត់ការស្រដៀងគ្នានេះពីប្រទេសថៃក្តី ក៏ក្រុមមន្ត្រីថៃមិនបានបញ្ជាក់ពីសេចក្តីរាយការណ៍ទាំងនេះទេ។

កាសែតបាងកកប៉ុស្តិ៍ បានរាយការណ៍កាលពីម្សិលមិញថា លោក ស៊ូថេប ថងស៊ូបាន ជាឧបនាយករដ្ឋមន្ត្រីថៃ និងលោក ថាវីល ភ្លីនស្រ៊ី ដែលជាអគ្គលេខាធិការនៃក្រុមប្រឹក្សាសន្តិសុខជាតិរបស់ថៃ បានធ្វើដំណើរទស្សនកិច្ចជាផ្លូវការ "បន្ទាន់" មួយមកកាន់ក្រុងភ្នំពេញកាលពីប្រកម្សិលមិញដើម្បីធ្វើការពិភាក្សាអំពី "ទំនាក់ទំនងតានតឹង" រវាងប្រទេសទាំងពីរនេះ។

លោក ផៃ ស៊ីផាន ជាអ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រីបានបញ្ជាក់ថា ជំនួបនេះមានមែន ប៉ុន្តែបានមានប្រសាសន៍ថាលោកគ្មានព័ត៌មានលំអិតអំពីអ្វីដែលត្រូវបានពិភាក្សាទេ។ ជំនួយការរបស់លោក ហ៊ុន សែន និងក្រុមមន្ត្រីខុទ្ទកាល័យមិនអាចទាក់ទងសុំការអត្ថាធិប្បាយបានទេ។

លោក កុយ គួង ជាអ្នកនាំពាក្យក្រសួងការបរទេសបានមានប្រសាសន៍ថា លោកមិនបានដឹងពីការមកដល់របស់លោក ស៊ូថេប នេះទេ ប៉ុន្តែបានអះអាងថា លោក កាស៊ីត បានមកដល់កាលពីរសៀលម្សិលមិញសម្រាប់កិច្ចប្រជុំថ្មីបំផុតរបស់គណៈកម្មការរួមសម្រាប់ទំនាក់ទំនងទ្វេភាគីរវាងប្រទេសកម្ពុជា និងប្រទេសថៃ ដោយបន្ថែមថា លោក កាស៊ីត និង ហោ ណាំហុង ជារដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជានឹងពិភាក្សាអំពី "គ្រប់វិស័យរវាងប្រទេសកម្ពុជា និងប្រទេសថៃ"។

មន្ត្រីថៃប្រហែល៤០នាក់ បានស្ថិតក្នុងខេត្តសៀមរាបសម្រាប់ថ្ងៃដំបូងនៃកិច្ចប្រជុំនេះហើយកាលពីម្សិលមិញ។

លោក ថានីត ថងធាកឌី ជាអ្នកនាំពាក្យក្រសួងការបរទេសថៃ មិនអាចធ្វើការទាក់ទងបានទេកាលពីម្សិលមិញ។ កាលពីថ្ងៃពុធ លោកបាននិយាយថាការផ្តន្ទាលោក វីរ៉ា មិនស្ថិតនៅក្នុងរបៀបវារៈនៃកិច្ចប្រជុំនេះទេ ប៉ុន្តែអាចនឹងត្រូវលើកយកមក ពិភាក្សាដែរ។

លោក ប៊ិច វិច្ឆិកា ជាមេធាវីមួយរូបក្នុងចំណោមមេធាវីរបស់ជនទាំងពីរនេះបានមានប្រសាសន៍ថា លោកនឹងប្តឹងឧទ្ធរណ៍នៅសប្តាហ៍ក្រោយនេះ។

នៅក្នុងទីក្រុងបាងកកណោះវិញ ក្រុមជាតិនិយមថៃបានគំរាមធ្វើបាតុកម្មតាមដងផ្លូវមួយក្នុងគោលបំណងផ្តួលរំលំរដ្ឋាភិបាល ប្រសិនបើរដ្ឋាភិបាលបរាជ័យក្នុងការទទួលបានការដោះលែងពួកគេត្រឹមថ្ងៃសៅរ៍នេះ ៕

(Continued from page 05 )

# Monk Accused of Sexually...

Should he choose to remain in Cambodia the American and Cambodian governments should work jointly to allow on-going cooperation to bring the case to justice."

A Revere woman comment, "This monk violated the basic core of the first five precepts already. If he has desire to be with a female he should have disrobed first. He brought bad name for other monks who are good Buddhist monks. Some individuals just wear the monk's robe and use religion for personal gain, underneath the robe they might as well a thief who enjoy being serve and taking care off."

A Revere man offers his comment, "A certain individual monks work their way from Cambodia to the U.S. for the right to legal residency and citizenship. Also as monk they can easily manipulate the innocent people for money. This is their way of making an easy living in the U.S."

**Responses from the member of the Community of Khmer Buddhist Monks Center of the United Stated and Canada**

The Most Venerable Dhammathero Sao Khon, president of the Community of Khmer Buddhist Monks Center of the United States of America, abbot of Wat Triratanaram North Chelmsford Massachusetts stated he does not have knowledge of Wat Angkorchum nor Por Venh.

The Maha Thera Ven. Dhammathero Sao Khon offers his knowledge on the accused situation relating to the individual monk, by stating, "The accused situation on such individual monk would be investigated by the Buddhist Monks Organization under the Buddha rules and Dharma virtues. All points of situation will be critically and thoroughly look into and consider from both the plaintiff and defendant, once all information and evidences collected and probable cause can be determent, judgment will be made. If the defendant found guilty he will right away be expelled and can never again in his life ordained to be a Buddhist monk. After being charged by the Buddhist Monks Organization the disrobed individual will turned to the society court of Law to be handle on the crime he committed. He has to face with two judgments the Religious and the Society Laws."

The Maha Thera Ven. Dhammathero Sao Khon also stated the accused situation caused major damage among Buddhist followers, their believe, confidence, and commitment to Buddhism. This act also dangerously injured and brings negative reflection on Buddhism.

The U.S. has 109 Khmer Buddhist Temples according to Templenews.org as of June 9, 2009. Maha Thera Ven. Dhammathero Sao Khon also stated, "I had called for a report for all Khmer Buddhist monks in the U.S. to report themselves and their Monastery/Temples or living quarter in the private home or apartment in the community as a way to Networks among the Khmer Buddhist Temples in the U.S. It is not successfully accomplished, as I am un-aware of Wat Angkorchum and the abbot of this temple who is being accused with the situation he did, without this knowledge I or the Buddhist Monks Organization cannot assist in the matter being accused."

Preah Maha Dr. Hok Savann of Montreal Canada was also contacted for this report, but he said he is not knowledgeable of the situation or accused monk Por Venh. Though, reported he has met two other monks from Wat Angkorchum in Philadelphia in the Fall of last year. He said he attempt to contact Wat Angkorchum to learn more about the accusation before he can provide knowledgeable comment. He was able to comment, "If the accused turns to be true, then he has to face with the religious and government Laws. But he cannot face with the government Law until he disrobed and become a layman."

There is 95% of the Cambodian population practice Theravada Buddhism. In this Buddhism form of practice when one ordains as a monk, one has usually already taken the Five Lay basic Precepts or Pali training rules out of 227 for Buddhist monks and 311 for Buddhist nuns. The five basic core precepts include:

1.Undertake the training rule of abstain from taking life

2.Undertake the training rule of abstain from taking what not given

3.Undertake the training rule to abstain from sexual misconduct that indulged in sexual relations with a female or male person or an underage person except their partner

4.Undertake the training rule to abstain from false speech

5.Undertake the training rule to abstain from fermented drink that causes heedlessness

According to Trent Walker, a scholar of "Cambodian Buddhism" who studied at the same Temple Por Venh did before moving to the U.S., said Por Venh came to the U.S. from Cambodia where he lived and studied in the Kandal Province before becoming abbot at Wat Angkorchum in Spring Texas. Venerable Vuthy Meas, another monk at Wat Angkorchum told ABC 13, "We built this temple in just three years."

ទស្សនៈវិស័យ :

# សូមកុំជេរនាយករដ្ឋមន្ត្រីថា អាក្បត់ជាតិ

ដោយ : ម៉ម យីន

••• ប្រជាពលរដ្ឋខ្មែរមួយចំនួន នៅពេលបើកវិទ្យុ អាស៊ីសេរីស្តាប់ កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០១១ ស្រាប់តែឮវិទ្យុនេះ ផ្សាយអំពីការព្រមានឱ្យដឹងជាមុន របស់លោកនាយករដ្ឋមន្ត្រីខ្មែរ ហ៊ុនសែន។ វិទ្យុអាស៊ីសេរី បានដកស្រង់សេចក្តីថ្លែងដោយសម្តេងផ្តាល់ថា " កុំថាឡើយមានអភ័យឯកសិទ្ធិ ឪអភ័យឯកសិទ្ធិ ក៏ត្រូវតែដកសិនដែរ ផ្តាំឱ្យហើយ! ជេរអី ជេរៗមករា ជេរចុះ ប៉ុន្តែជេរថា អាក្បត់ជាតិក្នុងហានៈ ជាអ្នកជាប់ឆ្នោត មានសម្តេងបោះឆ្នោតជូនពីប្រជាពលរដ្ឋ អីចឹងគេត្រូវតែធ្វើអ្នកឯទៃកុំលូកលាន់ បរទេសកុំលូកលាន់ តើនាយករដ្ឋមន្ត្រីបរទេសក្រៅអនុញ្ញាតឱ្យគេជេរថា ក្បត់ជាតិទេ? ប្រធានាធិបតីនៅលើពិភព លោកអនុញ្ញាតឱ្យគេជេរថា អាក្បត់ជាតិទេ? សុំផ្តាំទុកឱ្យហើយ ក្រែងលោវាមានរឿងហ្នឹងកើតឡើង"។

គ្រាន់តែបានឮពាក្យពេចន៍ថ្លែងផ្សាយចេញមកកាលពីថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ ដោយលោកនាយករដ្ឋមន្ត្រីហ៊ុនសែន នៅក្នុងឱកាសចែកសញ្ញាប័ត្រដល់និស្សិតនៅវិទ្យាស្ថានអប់រំក្រុងភ្នំពេញនេះភ្លាម គួរឱ្យរន្ធត់ក្តុកក្តួលក្នុងចិត្ត និងមានការសោកស្តាយខ្លាំងណាស់ គិតថា មិនគួរណាលោកនាយករដ្ឋមន្ត្រីដែលជាមេដឹកនាំកំពូលតំណាងឱ្យប្រទេស និងប្រជាជាតិខ្មែរទាំងមូល។ លោកប្រើពាក្យពុំសមរម្យទៅកាន់អស់លោកជាសភាតំណាងប្រជាពលរដ្ឋនៃរដ្ឋសភាជាតិខ្មែរ ដែលប្រជាពលរដ្ឋបានបោះឆ្នោតជ្រើសរើសឱ្យទៅធ្វើជាតំណាងរបស់ខ្លួនពេញលក្ខណៈច្បាប់រដ្ឋធម្មនុញ្ញ។ ប៉ុន្តែមិនតែប៉ុណ្ណោះតំណាងប្រជាពលរដ្ឋនេះ ច្បាប់រដ្ឋធម្មនុញ្ញបានការពារដោយផ្តល់ឱ្យមានអភ័យឯកសិទ្ធិ មានន័យថា សេចក្តីសម្រេចតាមអំណាចច្បាប់ គឺជាអំណាច ដោយឡែកការពារមិនឱ្យមានភ័យ ឬជាច្បាប់ពិសេសសម្រាប់ជនមួយរូប ឬមួយក្រុម ឬជាសេចក្តីសម្រេចតាមអំណាចច្បាប់ផ្សេងដោយឡែកសម្រាប់លស់លាឱ្យរួចទោស។

ដូច្នេះសភាតំណាងប្រជាពលរដ្ឋនៅគ្រប់ប្រទេសនានាសុទ្ធតែទទួលនូវច្បាប់ពិសេស គឺអភ័យឯកសិទ្ធិនេះដូចគ្នាទាំងអស់ ដើម្បីឱ្យសភាតំណាងប្រជាពលរដ្ឋមានសិទ្ធិអំណាចគ្រប់គ្រាន់នៅក្នុងស្ថាប័ននិតិបញ្ញត្តិ តាមដាននិងពិនិត្យលើការអនុវត្តន៍ បន្ទាត់ឥរិយោបាយរបស់រដ្ឋាភិបាលដែលជាស្ថាប័ននិតិប្រតិបត្តិបំរើផលប្រយោជន៍និងប្រជាពលរដ្ឋខ្មែរ។

នៅក្នុងសេចក្តីព្រមានរបស់លោកនាយករដ្ឋមន្ត្រីនេះស្តាប់ទៅឃើញថា មានទម្ងន់ខ្លាំងណាស់ គឺអ្នកដែលប្រព្រឹត្តខុសនេះ ត្រូវតែមានទោសធ្ងន់រហូតដល់អាប់អោនកិត្តិយស អស់បុណ្យស័ក្តិន អស់មុខតំណែង អស់ប្រាក់ប្បេវិត្យរ៍ សរុបសេចក្តីទៅ គឺត្រូវអស់អនាគត ត្រូវរស់នៅទាំងរងទុក្ខវេទនាតាមយថាកម្មអស់មួយជីវិត។

ចំពោះពាក្យជេរប្រមាថគ្រប់បែបយ៉ាង ដែលមនុស្សម្នាក់បានផ្ញើទៅលើមនុស្សម្នាក់ទៀត វាពុំដែលកើតមានដោយចៃដន្យទទេៗនោះទេ គឺសុទ្ធតែមានហេតុបច្ច័យដូចជាមនុស្សឈ្លោះទាស់ទែងគ្នា មនុស្សសត្រូវស្តាប់រស់ជាមួយគ្នា មនុស្សរំលោភបំពានផ្លូវកាយផ្លូវចិត្តដោយគ្មានគោរពគ្នាជាដើម។

ប៉ុន្តែបើសិនជាមនុស្សរស់នៅក្នុងសង្គមជាតិដូចគ្នាជាបងប្អូនសាច់ឈាមជាមួយគ្នា គេពុំត្រូវបានការជេរប្រមាថកាតទានគ្នានោះទេ។

ប្រធានាធិបតីក្តី នាយករដ្ឋមន្ត្រីក្តី និងមន្ត្រីនានាក្តី ដែលជាបុគ្គលសាធារណៈ បានដាក់ចិត្តគំនិតដាក់កាយមកធ្វើកិច្ចការបំរើសាធារណជន គឺប្រជាពលរដ្ឋទូទាំងប្រទេស ត្រូវតែប្រកាន់យកខ្ជាប់ខ្ជួននូវគុណធម៌ សីលធម៌ សច្ចធម៌ និងយុត្តិធម៌ ជាពិសេស ត្រូវមានបុគ្គលិកលក្ខណៈជាអ្នកមានគតិបណ្ឌិតពិតប្រាកដ ប្រាស់ចាកអគតិទាំង៤ គឺ : ១-ឆន្ទាគតិ លំអៀងព្រោះស្រឡាញ់, ២- ទោសាគតិ លំអៀង ព្រោះស្អប់, ៣-ភយាគតិ លំអៀងព្រោះភ័យខ្លាច, ៤-មោហាគតិ លំអៀងព្រោះល្ងង់ខ្លៅ ទើបមានគុណសម្បត្តិ សមត្ថភាពពេញលក្ខណៈជាមេដឹកនាំ។

ដរាបណាមេដឹកនាំបានបំពេញនូវគុណសម្បត្តិ និងសមត្ថភាពពេញលក្ខណៈល្អប្រពៃហើយ ដរាបនោះ ពុំមានសភាតំណាងប្រជាពលរដ្ឋ ឬប្រជាពលរដ្ឋណាមួយជេរថា អាក្បត់ជាតិនោះទេ មានតែនាំគ្នាគោរពលើកតកើង កោតសរសើរ កោតខ្លាច ហើយឧទ្ទេសនាមថា ជាអ្នកស្នេហាជាតិពិតប្រាកដទៀតផង។

ចំណែកប្រធានាធិបតី នាយករដ្ឋមន្ត្រីបរទេសមក្រៅគេពុំដែលអនុញ្ញាតឱ្យជេរថា អាក្បត់ជាតិមែន ប៉ុន្តែលុះត្រាតែប្រធានាធិបតី ឬនាយករដ្ឋមន្ត្រីនោះបានដឹកនាំប្រទេសជាតិបានប្រកបដោយគតិយុត្តិធម៌ និងគតិបណ្ឌិតពិតប្រាកដមែន។ ផ្ទុយទៅវិញ ប្រសិនបើប្រធានាធិបតី ឬនាយករដ្ឋមន្ត្រីនោះ ប្រព្រឹត្តិធ្វើនូវអំពើណា ពុំមានសម្រេចជោគជ័យដូចពាក្យសន្យាឱ្យមានឧបទ្ទវហេតុអ្វីមួយនៅក្នុងក្របខ័ណ្ឌទទួលខុសត្រូវរបស់ខ្លួន ពេលនោះត្រូវតែមានឆន្ទៈអង់អាចក្លាហាន សុំលាឈប់ពីតំណែងភ្លាម បើមិនដូច្នេះទេ នៅពេលចប់អាណត្តិប្រជាពលរដ្ឋត្រូវតែបោះឆ្នោតទម្លាក់ពីតំណែងដែរ។

ចំពោះលោកនាយករដ្ឋមន្ត្រីខ្មែរ ហ៊ុនសែន ដែលលោកបានថ្លែងថា ពុំមាននាយករដ្ឋមន្ត្រីបរទេសក្រៅណាអនុញ្ញាតឱ្យជេរថា អាក្បត់ជាតិ គឺមានអតីតនាយករដ្ឋមន្ត្រី ឧត្តមសេនីយ៍តម្រូត តាក់ស៊ិន ជិនណាវ៉ាត់ ប្រទេសថៃ ត្រូវបានក្រុមសម្ព័ន្ធមិត្តអាវ ល្បើង ជេរថា អាក្បត់ជាតិថៃ លក់ដី លក់ផ្តាយ រណបថៃឱ្យទៅសិង្ហបុរី ត្រូវចុះចេញពីតំណែង ចេញទៅ ចេញទៅ ចេញទៅ រហូតដល់បណ្តាលឱ្យកងទ័ពជាតិថៃ ធ្វើរដ្ឋប្រហារដកចេញពីតំណែង ដូចពាក្យជេរ អាវល្បើង នោះមែន។

ដូច្នេះលោកនាយករដ្ឋមន្ត្រីខ្មែរ ហ៊ុនសែន បានព្រមានដល់សភាតំណាងប្រជាពលរដ្ឋ កុំឱ្យជេរលោក និងមន្ត្រីនានាថា អាក្បត់ជាតិនោះ វាស្រែចនៅលើរូបលោកទេ បើសិនជាលោកមិនចង់ឱ្យគេជេរ សូមលោកនាយករដ្ឋមន្ត្រី មេត្តាបញ្ឈប់នូវទង្វើការប្រព្រឹត្ត និងថ្លែងអះអាងអះអាងដែលសំដែងចេញឱ្យឃើញ និងដឹងថា លោក និងមន្ត្រីកំពុងតែអនុវត្តន៍ប្រព័ន្ធឥរិយោបាយដឹកនាំប្រទេស និងជនជាតិខ្មែរឱ្យធ្លាក់ទៅក្នុងមហិច្ឆិតាលោភលន់នៃប្រទេសជិតខាងជាតិយួន ដែលជាមហាគ្រោះថ្នាក់ មហន្តរាយ មហាហាយនដល់ប្រទេស និងប្រជាជាតិខ្មែរនៅពេលអនាគតដ៏ខ្លីខាងមុខនេះ ។

(តទៅទំព័រទី ១៤)

*(Continued from page 02 )*

# Lowell Youth Present:...

Veth said, "Art is a way for youths to reflect and heal." Through art, "they can draw out thoughts and feelings of what happened." Johnny Tran 17, LCHC Teen Peer leader acknowledged the audience as a host of the event, "The art is for sharing, not to be judge, as expression has no right and wrong."

Both Veth and Tran said the goal of the Exhibit is to show Lowell that the young people do care and understand what happened in the community and that this event is to "brighten up the moral" of the community, bring about the good environment and that the community shouldn't be scared.

Paula Em 15 from "Free Verse", an organization whose mission is "to introduce and nurture the culture of spoken word poetry in the city of Lowell" stated, "What you see today is a little piece of what you'll see in the future." Em give a reassuring smile with humble enthuse. Suty Komsonkeo 17 also from Free Verse shared, "What we are doing here shows how might we want to come together, that it is an alternate ways of approaching life in stead of violent."

Linda Sou, Director of LCHC Teen Coalition reported, "This is the first event of the Art Exhibit." Sou a former graduated Teen Coalition herself shared the frustration that all the good things that are done by young people are being overshadowed by the negative events and they often feel "not being heard." Sou continued "Youth do care and they want to see change."

Nick and Nate Timm 17, a twin brothers are seniors at Lowell High School and youth leaders at LCHC also shared, "Youths work together to make change. People (referred to young people) are actually do care about what happened in the community." Another youth from Lynn, Tino Hem, 17 participated in "The Line" activity comment, "the purpose of this event is to stop violent, help community to come together"

Hem is a student at Lynn Classical High School and a peer leader from Khmer American Youth in Action (KAYA) a program of Lynn Community Health Center. Besides being a peer leader Hem also keeps himself busy with both the school and community football teams.

Harry Schnur, a Lynn Community Health Worker and youth program facilitator for KAYA said about the Art Exhibit, "Spectacular and inspirational. It is made for young people to come together after a tragedy." He continued saying about the event, "shows tremendous talent of youth in Lowell. Audience show support, they (youths) show support for each other. This sends a powerful message." According to Lynn Community Health Center, Khmer American Youth in Action (KAYA) is a "youth- driven project focused on promoting healthy behavior in the Lynn community and helping each other succeeds in school, at home and in life."

Lowell Health Community Teen Coalition is a Youth-Driven Prevention Programs focusing on preventing youth violence, teen pregnancy, HIV/AIDS and STIs, and substance abuse through Educational retreats, Cultural enrichment, Strengthening family connections, Art and dance, Tutoring, and Mentoring.

Sou reported, "We serve 80 youths on a daily basis and almost 100% of our youths are self referred/volunteered to be in the program. We do welcome referral."

According to Dorcas Grigg-Saito, CEO of Lowell Health Community Center (LCHC) stated in the program Community Link Newsletter of Spring 2010, "Seventy-five percent of deaths in adolescents are related to social and behavioral factors, so we need more than medical care to promote strong and resilient youth."

LCHC also offers a specific support program for Cambodian youth called, "Journey to Healing Project For Cambodian Youth." This program offers a 8-12 week workshop twice a year-during Spring and Fall to Cambodian-American youths who are second generation effected by PTSD, resulting from traumatic experience in Cambodia. From this program youths are able to learn healthy and positive coping skills in dealing with PTSD and improve better understanding within family relationships.

LCHC Teen Coalition conducts quarterly education/awareness events which include:

+APRIL - National Alcohol Screening Day, Kick Butts Day, Take It Back

+MAY – National Day to Prevent Teen and Unplanned Pregnancies

+ June – Youth Recognition Ceremony to recognize youth efforts and provide a night of appreciation

+ AUGUS – Dance 4 Peace Violence Prevention Event

+ NOVEMBER – Youth kick-off event to World AIDS Day

For more information contact: (978) 322-8531

ឆាទី ប្រវត្តិសាស្ត្រ

# ពីរដ្ឋបាលកុលសម្ព័ន្ធមកដល់រដ្ឋាភិបាលសម័យ

**ប្រែសម្រួលដោយ : ពិន សំខុន (តពីលេខមុន)**

**•៣០ មិថុនា** : ទស្សនៈកិច្ចរបស់តាំងអង្គការសហប្រជាជាតិ វ៉ាហ្គីឌីន អាមេរិក នៅភ្នំពេញ។ ការដកទ័ពមួយចំនួនរបស់វៀតណាម។ អគ្គលេខាធិការជួរមុខរបស់វៀតណាមនៅកម្ពុជា បានត្រូវដកទៅដាក់នៅខេត្តតាយនិញ ។

**•០៤ កក្កដា** : ចាប់ទូកនេសាទថៃប្រមាណ២០ នៅក្បែរមូលដ្ឋានយោធា "រឿម" មូលដ្ឋានយោធានោះ ជួសជុល និងសាងសង់ឡើងវិញ ដោយវៀតណាម និង សូវៀត។

**•១០ កក្កដា** : សីហនុ លាលែងពីតំណែងប្រធានរដ្ឋាភិបាលសម័ន្ធម្តងទៀត។ នេះជាការលាលែងលើកទី៦ ចាប់តាំងពីកំណើតរដ្ឋាភិបាលសម័ន្ធកម្ពុជាប្រជាធិបតេយ្យមក។ ការលាលែងនេះចង់សំដែងប្រឆាំងពីការវាយប្រហាររបស់ទ័ពខ្មែរក្រហមមកលើទ័ពសីហនុនិយម ហើយនិងការគាំទ្ររបស់ចិន ចំពោះក្រុមខ្មែរក្រហម។ ព្រះអង្គបានតែងតាំងទ្រង់នរោត្តមរណឫទ្ធិ ឱ្យជំនួសតំណែងព្រះអង្គ ហើយលោកក៏ទ្រង់យាងទៅប្រទេសបារាំង ជួបនឹងរដ្ឋមន្ត្រី រ៉ូឡង់ ឌុយម៉ាស ។

**•១១ កក្កដា** : ប្រជុំរដ្ឋមន្ត្រីការបរទេសអតីតឥណ្ឌូចិនទាំងបី នៅភ្នំពេញ។ សេចក្តីថ្លែងការណ៍តូសបញ្ជាក់ពី : ១- ការដកទ័ពវៀតណាមត្រឡប់ចូលប្រទេសខ្លួនយ៉ាងឡៃតទាត់។ ២- ប្រឆាំងនឹងការត្រឡប់របស់ក្រុម ប៉ុល ពត។ ៣- មិនពេញចិត្តចំពោះសហគមន៍អាស៊ាន ដែលមិនបង្ហាញការចាប់អារម្មណ៍ទៅលើការវិវត្តន៍ផ្លូវទូត ដែលនាឱកាសថ្មីៗនេះការលើកសេចក្តីថ្លែងការរួម ឥណ្ឌូនេស៊ី និងសូវៀតបានចូលរួមក្នុងគំនិតធ្វើឱ្យអាស៊ីអគ្នេយ៍ក្លាយជាតំបន់មានសន្តិភាព (២៩ កក្កដា ១៩៨៧) នៅខែជាមួយគ្នានោះ សភារដ្ឋកម្ពុជាសម្រេចប្តូរមាត្រា ១២ និង ១៩ នៃរដ្ឋធម្មនុញ្ញ ដោយចង់បញ្ចូលកម្ពុជានៅក្នុងចរន្តទីផ្សារសេរី។

**•២៣ កក្កដា ១៩៨៨** : សម្តេច សីហនុ ទៅធ្វើទស្សនៈកិច្ចនៅឥណ្ឌូនេស៊ី ដោយការអញ្ជើញរបស់ប្រធានាធិបតី សូហាតូ ។ ព្រះអង្គបានប្រកាសថា "មិនចូលរួមប្រជុំក្រៅផ្លូវការណ៍" ដែលនឹងត្រូវធ្វើនៅពីរថ្ងៃខាងមុខនោះទេ។

**•២៤-២៨ កក្កដា** : សម្តេច សីហនុ ដែលមិនបានចូលប្រជុំ បានត្រូវតំណាងភាគីខ្មែរទាំងបួនសុំចូលគាល់ ហើយបង្ហាញផែនការ៥ចំណុច ដែលមាន: ១- សម្រេចកំណត់រូបមន្តរួម ដើម្បីសម្តាល់កម្ពុជា។ ២- បង្កើតរដ្ឋាភិបាលចម្រុះចតភាគី (រដ្ឋមន្ត្រីបួនក្នុងទីស្តីការនីមួយៗ)។ ៣- បង្កើតកងទ័ពចម្រុះមានបួនភាគី។ ៤- រៀបចំការគ្រប់គ្រងរដ្ឋបាលចំរុះម្តងបន្តិចៗ ចេញពីរដ្ឋបាលរដ្ឋកម្ពុជា។ ៥- រៀបចំប្រជុំសន្តិសីទអន្តរជាតិ ដើម្បីធានាអព្យាក្រិត្យភាពនៃកម្ពុជា។ បញ្ជូនអង្គការឃ្លាំមើលអន្តរជាតិឱ្យត្រួតត្រាការដកទ័ពវៀតណាម ចេញពីកម្ពុជា ហើយនឹងជ្រោមជ្រែងការគ្រប់គ្រងរបស់រដ្ឋបាលចតភាគីឱ្យអាចរក្សាសន្តិភាព សន្តិសុខ និងគ្រប់គ្រងការបោះឆ្នោតដោយសេរីមួយ។

នៅចុងបញ្ចប់នៃកិច្ចប្រជុំបួនថ្ងៃ ដែលចំណុចយល់ស្របគ្នាបានរកឃើញហើយនោះ ក្រុមខ្មែរក្រហមបានជំទាស់នឹងសេចក្តីថ្លែងការណ៍រួម លោក អាលី អាឡាតាស់ រដ្ឋមន្ត្រីការបរទេសឥណ្ឌូនេស៊ី បានប្រកាសថា "ដំណោះស្រាយទាំងអស់ ត្រូវឆ្លងកាត់ដកទ័ពវៀតណាមទាំងអស់ចេញពីកម្ពុជា។ សម្រេចផែនការតប់ស្កាត់មិនឱ្យរបបសម្លាប់រង្គាលត្រឡប់មកកាន់កាប់កម្ពុជាវិញបាន ហើយចុងបញ្ចប់មិនឱ្យបរទេសណាជ្រៀតជ្រែកកម្ពុជាបានឡើយ។ ក្រុមការងារដែលមានភារកិច្ចបកស្រាយដំណោះស្រាយនយោបាយ បានត្រូវបង្កើតឡើង។ សីហនុ និង ហ៊ុនសែន សន្យានឹងជាគ្នាជាថ្មីនៅប្រទេសបារាំងនាខែតុលា ខាងមុខ។

**•៣០ កក្កដា** : នៅពេលដែលត្រឡប់មកដល់ប៉េកាំងវិញ សម្តេច សីហនុ ថ្លែងថា: ខ្មែរក្រហមគឺជាឧបសគ្គចំបងសម្រាប់ដំណោះស្រាយសន្តិភាពកម្ពុជា ទីភ្នាក់ងារចិនថ្មី បានផ្សាយនៅថ្ងៃដដែលថា "ពុំមានរឿងហេតុអ្វីដែលនាំឱ្យដកទ័ពខ្មែរក្រហមចេញនោះទេ"។

**•០១ សីហា** : សម្តេច សីហនុ ទទួលលោកស្រី នាយករដ្ឋមន្ត្រីអង់គ្លេស ថាច់ ឈើ នៅសាយប៊ុ (Site B) ព្រះអង្គបានថ្លែងថា : "មិនយល់ទាននឹងការទុកអាសនៈខ្មែរ នៅអង្គការសហប្រជាជាតិឱ្យនៅទំនេរនោះទេ ហើយរដ្ឋាភិបាលព្រះអង្គគ្រាន់តែជារនាំងការពារខ្មែរក្រហមតែប៉ុណ្ណោះ"។

**•០៥ សីហា** : ភាគីខ្មែរក្រហមបញ្ចេញផែនការសន្តិភាព ដែលមាន១៤ចំណុច ដែលចាំបាច់ឱ្យមានការចូលរួមក្រុមខ្លួនអនាគតអំណាចខ្មែរ។ ការដកទ័ពវៀតណាមឱ្យអស់ និងរំលាយរដ្ឋកម្ពុជាចេញ ។

**•២០ សីហា** : រើសរដ្ឋាភិបាលរដ្ឋកម្ពុជា :

**១. រដ្ឋាភិបាល ហ៊ុនសែន (ពីថ្ងៃទី២០ សីហា ១៩៨៨ មកដល់ថ្ងៃ០១ សីហា ១៩៨៩)**

. នាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីការបរទេស : ហ៊ុនសែន
. ឧបនាយករដ្ឋមន្ត្រី : ប៊ូ ថង
. ឧបនាយករដ្ឋមន្ត្រី : ជា សុទ្ធ
. ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីកសិកម្ម : សាយ ឈុំ
. ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីការពារជាតិ : ទា បាញ់
. ឧបនាយករដ្ឋមន្ត្រី : គង់ សំអុល
. រដ្ឋមន្ត្រីយុទ្ធជនពិការ និងសង្គមកិច្ច : កុយ ប៊ុនថា
. រដ្ឋមន្ត្រីត្រួតពិនិត្យកិច្ចការរដ្ឋ : គង់ គាំ
. រដ្ឋមន្ត្រីផែនការ : ជា ចាន់តូ
. រដ្ឋមន្ត្រីមហាផ្ទៃ : ស៊ិន សុង
. រដ្ឋមន្ត្រីឧស្សាហកម្ម : អ្នកស្រីហួ ណួន
. រដ្ឋមន្ត្រីពាណិជ្ជកម្ម : តាំង សារឹម
. រដ្ឋមន្ត្រីប៊ិរញ្ញវត្ថុ : ឆាយ ថន
. រដ្ឋមន្ត្រីអប់រំជាតិ : ប៉ែន ណាវុធ
. រដ្ឋមន្ត្រីសុខាភិបាល : យិត គីមសេង
. រដ្ឋមន្ត្រីឃោសនាការ និងវប្បធម៌ : ឆេង ផុន
. រដ្ឋមន្ត្រីយុត្តិធម៌ : អ៊ុក ប៊ុនឈឿន
. រដ្ឋមន្ត្រីទូរគមនាគមន៍-ដឹកជញ្ជូន និងប្រៃសណីយ៍ : អ៊ុង ផន
. រដ្ឋមន្ត្រីគមនាគមន៍ : ឃុន ឈី
. រដ្ឋមន្ត្រីទទួលបន្ទុកចំការកៅស៊ូ : សំ សារិទ្ធ
. រដ្ឋមន្ត្រីអមទីស្តីការគណៈរដ្ឋមន្ត្រី : ហោ ណាំហុង
. រដ្ឋមន្ត្រីគ្មានដំណែង : ពុង ប៉ែងចេង
. នាយកធនាគារជាតិ : ចា វ៉ឿង

**(នៅមានតលេខក្រោយទៀត)**

ឆាទី ព្រះពុទ្ធសាសនា

# ពុទ្ធប្បវត្តិអមដោយរូបភាព

# A Pictorrial Biography of Saky amuni Buddha

- រូបភាព និងរឿងដើមជាភាសាថៃ ដោយ គុណាប៉ាយុតា
- បកប្រែជាភាសាអង់គ្លេស ដោយ ហ្សឺត .អេ.លី
- ផាត់ពណ៌ដោយ យ៉ាន់ ហ្វាលី
- បកប្រែជាភាសាខ្មែរដោយភិក្ខុ គង់ អាំ

- Original Illuatration and Naration in Thai by Gunapayuta.
- Translation into English by A Lu.
- Coloring by Yann Fang Lee
- Translation into Khmer by Bhikkhu Kong Am.



114- One morning a girl named Sujata, who lived in the village, cooked a pot of delicious rice milk porridge and brought if over as an offering to Siddhartha. After presenting the offering, the noble girl said: "I wish you success in your aspiration as I have succeeded in my aspiration! "Siddhartha ate the parried she offered him and felt it was very beneficial in improving both his physical and mental stamina.

**Sujata** had made a wish that a child be born to her and then she offered food to Siddhartha to show her gratitude.

114- That same day, Siddhartha went for a bath in the Nairanjana River; then he sat down under a Sala tree by the riverbank and concentrated himself in meditation, hoping to attain enlightenment in the silence of the night when no one might be passing by. At dusk Siddhartha left the Sala tree and walked to a large Bodhi tree, which he had chosen previously as the place for his meditation. On the way he met a straw-peddler named Sotthiya and accepted from him an offering of a bunch of straw. So he made a seat with the straw and sat down under the large Bodhi tree, facing east.

*(Continued After Isssue)*

**(នៅមានតលេខក្រោយ)**


# DRANOFF ASSOCIATES

*Attorneys at Law*

"ដ្រាណូហ្វ អាសូស៊ីយេត (DRANOFF ASSOCIATE) គឺជាមណ្ឌលការពារតាមផ្លូវច្បាប់ ដែលធ្វើការប្រកបដោយភក្តីភាព ដើម្បីតំណាងឱ្យអ្នករងគ្រោះ ដែលមានរបួសរូបរាងកាយ ។

ស្ទីវិន ដ្រាណូហ្វ (STEVEN DRANOFF) គឺជាមេធាវីនៅសាលាក្តីមានបទពិសោធន៍យ៉ាងខ្ពស់ខាងសេវាច្បាប់ ៣៥ឆ្នាំ ។

យើងធ្វើការដោយយកកំរើពីការងារដែលប្រគល់ឱ្យលោកអ្នកមិនចាំបាច់ចេញថ្លៃចំណាយអ្វីមុននឹងលោកអ្នកទទួលប្រាក់សងពីមុខរបួសលោកអ្នកនោះទេ ។

ជំនួយខាងផ្លូវច្បាប់អាចផ្តល់ជូនជាភាសា ស្បានីស ខ្មែរ វៀតណាម កូរ៉េ និង ចិន ។

● **របួសលើរាងកាយ** : គ្រោះថ្នាក់រថយន្ត, ឡានឈ្មួល "សិបកា", ឡានត្រីក, តាក់ស៊ី, ជិះកង់, ថ្មើរជើង, រអិលដួលលើទឹកកក, លើចិញ្ចើមថ្នល់ ឬក្នុងអាគារលក់ទំនិញ, គ្រោះថ្នាក់ដោយបានទិញរបស់ខូចមកប្រើ ឬក៏ឆ្កែខាំ... ។

● **ការប្រហែសក្នុងវិជ្ជជីវៈ និងសិទ្ធិរបស់អតិថិជន** : ព្យាបាលតាមវិជ្ជាពេទ្យពុំបានត្រឹមត្រូវ, មរណភាពឥតសមហេតុផល, រាយមាយក្នុងការថែទាំមនុស្ស... ។

DRANOFF ASSOCIATES

121 South Broad Street, Suit 1210, Philadelphia, PA 19107
215-732-3333 (phone) 215-732-8059 (fax)
sdranoff@dranofflaw.com

# អាថ៌កំបាំង និងសិល្បៈនៃជីវិត
# SECRET AND ART OF LIVING

(តមកពីលេខមុន)

រៀបរៀងដោយ
លោក ម៉ៅ ច័ន្ទសំណុំ

● ជីវិតរស់នៅក្នុងម៉ែមីរីងាយណាស់យើងដឹងគ្រប់គ្នាព្រោះជាជីវិតជាក់ស្តែងរាល់ថ្ងៃ។ ការលំបាកបានដល់ការរស់នៅខាងក្រៅម៉ែមីរី តើធ្វើយ៉ាងណា? តើធ្វើដូចម្តេច? មនុស្សទាមទារឱ្យមានចំណេះដឹងនិងសិល្បៈប្រើប្រាស់ចំណេះទាំងនោះក្នុងជីវិតជាក់ស្តែង ។

អារ្យធម៌ វប្បធម៌ មនុស្សជាច្រើនជំនាន់បានឆ្លុះបញ្ចាំងវិធីជាច្រើនយ៉ាងដូចជាការប្រតិបត្តិសាសនានានា ការហាត់យោគៈ (Yoga) ការសូត្រពាក្យម៉ាន់ត្រា ការប្រតិបត្តិសមាធិបែក១ការហាត់តាំងសតិឱ្យនៅនឹងពេលបច្ចុប្បន្ន ការហាត់ក្បួនបូរាណចិន zen, Tai-chi, Taoism ការហាត់សមាធិតាមក្បួនបូរាណជប៉ុន koan ការហាត់ប្រមូលសតិ (Concentration) លើវត្ថុនានាដូចជាអណ្តាតភ្លើង ផ្កា លំហអាកាស ធម្មជាតិជុំវិញ ។ល។

ប្រទេសកម្ពុជាយើង មានភ័ព្វសំណាងយ៉ាងក្រៃលែង ដោយមានព្រះពុទ្ធសាសនាជាគ្រឹះជួយខ្មែរឱ្យស្គាល់សេចក្តីសុខចំរើន និងសុភមង្គលក្នុងជីវិតគ្រប់ប្រការ។ សមាធិវិបស្សនាជាបច្ចេកទេសមួយដ៏អស្ចារ្យរបស់ព្រះពុទ្ធសាសនា ដែលខ្ញុំសូមអធិប្បាយលំអិតខាងក្រោម :

**សមាធិវិបស្សនា :**

ទិសដៅសំខាន់បំផុតរបស់ព្រះពុទ្ធសាសនាគឺបានដល់ការរំដោះអ្នកប្រតិបត្តិធម៌ឱ្យរួចផុតពីទុក្ខវេទនាក្នុងជីវិតរស់នៅជាក់ស្តែង ហើយបានឃើញពន្លឺព្រះនិព្វានបរមសុខក្នុងពេលបច្ចុប្បន្ន និងទៅអនាគតកាលខាងមុខត១រឿងទៅ។ អ្នកប្រតិបត្តិនឹងពិសោធឃើញសេចក្តីសុខក្នុងជាតិជាមនុស្សនេះពុំចាំរង់ចាំដល់ជាតិក្រោយ១ឡើយ។ ខ្ញុំផ្ទាល់បានប្រតិបត្តិសមាធិវិបស្សនាតាមមាគ៌ាព្រះពុទ្ធសាសនាអស់រយៈជាង១០ឆ្នាំមកនេះ ពិតជាជួបនឹងសេចក្តីស្ងប់ផ្លូវចិត្ត សន្តិភាពផ្លូវចិត្ត ជីវិតមានពន្លឺរស្មី និងប្រកបដោយភាពរីករាយ ត្រជាក់ត្រជុំ សុភមង្គល ទោះបីជីវិតជួបនឹងឧបស័គ្គចំរូងចំរៃយ៉ាងណាក៏ដោយ (ដូចជាជម្ងឺភាពខ្វះខាត ការបាត់បង់មនុស្សជាទីស្រឡាញ់) ។ល។ សូមឧទ្ទិសមនុញ្ញផលនិងការដឹងគុណដ៏ជ្រាលជ្រៅជូនដល់ក្រុមវិបស្សនានៅទីក្រុងហ្វីឡាដែលហ្វ្រៃសហរដ្ឋអាមេរិក ដែលបានជួយឧបត្ថម្ភរូបខ្ញុំ និងគ្រួសារឱ្យរួចរំដោះពីទុក្ខសោកក្នុងបច្ចុប្បន្នជាតិនេះ។ ខ្ញុំសូមចែករំលែកការពិសោធន៍ និងចំណេះដឹងក្នុងផ្នែកនេះ តាមរយៈអត្ថបទដែលអ្នកកំពុងអានសំរាប់ជាប្រយោជន៍ដល់កូនខ្មែរជំនាន់ក្រោយ១ និងសំរាប់ជាបុព្វហេតុសន្តិភាពសកលលោក ។

តើអ្នកជ្រាបឬទេថា តើបណ្ដុល ខ្លឹម មូលដ្ឋានគ្រឹះនៃព្រះពុទ្ធសាសនាឋិតនៅលើចំណុចណា ?

ព្រះពុទ្ធសាសនាមានគោលការណ៍គ្រឹះ៣យ៉ាងគឺ សីល សមាធិ និង បញ្ញា ។ សីល : ការរស់នៅក្នុងធម្មចរិយា. សមាធិ : ការធ្វើម្ចាស់នៃចិត្ត. បញ្ញា : ការស្គាល់របៀបបដិបត្តិដើម្បីរំដោះខ្លួនចេញពីទុក្ខ។

រូបមន្តទាំងបីនេះ បើជនណាប្រតិបត្តិបានពេញលេញ គេនឹងពិសោធព្រះនិព្វានក្នុងជាតិនេះពុំខានឡើយ។ អ្នកប្រហែលជាកើតចម្ងល់ដូចខ្ញុំ «តើព្រះនិព្វានជាអ្វីទៅ?» ។ ខ្ញុំតែងឮចាស់ៗដំណាលតៗគ្នាថា «ចូររក្សាសីល និងដាក់ទានប្រាថ្នាឱ្យបានជួបនឹងព្រះនិព្វាន» យើងពុំដឹងជាជាតិណាទេ ទើបឃើញពន្លឺព្រះនិព្វាន។ តាមពិតព្រះពុទ្ធពិសោធឃើញព្រះនិព្វានក្នុងព្រះកាយនៅពេលដែលព្រះអង្គនៅមានព្រះជន្មជាមនុស្សដូចយើងរាល់គ្នានៅឡើយ។ ព្រះអង្គបានខិតខំផ្សព្វផ្សាយនូវវិធីធ្វើយ៉ាងណាឱ្យយើងម្នាក់ៗអាចពិសោធឃើញព្រះនិព្វានពិតប្រាកដដូចព្រះអង្គ។ ការសន្និដ្ឋានដែលខ្ញុំជំរាបខាងលើនេះ បានមកអំពីការពិសោធន៍ប្រតិបត្តិសមាធិវិបស្សនាកន្លងមក ។

ខ្ញុំសូមបរិយាយបន្តនូវរូបមន្តទាំងបីនេះ គេអាចបំបែកលំអិតជា៨ប្រការ :

ទី១- សីលបំបែកជា : សម្មាវាចា (វាចាត្រូវ) សម្មាកម្មន្ត (ការងារត្រូវ) សម្មាអាជីវៈ (ការចិញ្ចឹមជីវិតត្រូវ) ។

ទី២- សមាធិបំបែកជា : សម្មាវាយាមៈ (ព្យាយាមត្រូវ) សម្មាសតិ (ការរលឹកត្រូវ) សម្មាសមាធិ (សមាធិត្រូវឬការដឹកលំចិត្តត្រូវ) ។ ទី៣- បញ្ញាបំបែកជា : សម្មាទិដ្ឋិ (ការយល់ត្រូវ) សម្មាសង្កប្ប : (ការត្រិះរិះត្រូវ) ។

បន្តទៅនេះ ខ្ញុំនឹងលើកដំពូកទាំងបីនេះមកអធិប្បាយលំអិតដូចតទៅ :

**ក- សីល (Morality) :**

អ្នកកាន់ព្រះពុទ្ធសាសនារក្សាសីល៥ :

១- អហិង្សា (Ahimsa ) : ពុំប្បែតប្បែនជីវិតការប្រកាន់ធម៌អហិង្សា។ សត្វទាំងអស់ក្នុងលោកពុំចង់ជួបនឹងគ្រោះថ្នាក់ឬការប្បែតប្បែនជីវិតដោយប្រការណាមួយឡើយ។ ខ្លួនយើងផ្ទាល់ម្នាក់ៗក៏ដូច្នោះដែរ។ ដូច្នេះដើម្បីឱ្យជីវិតប្រពឹត្តទៅបានរលូនស្របស្រួលគ្នា គប្បីមនុស្សម្នាក់ៗកាន់ធម៌អហិង្សានេះជាចាំបាច់ ។

២- សច្ចធម៌ (Truthfulness) និយាយ និងប្រព្រឹត្តតាមសច្ចធម៌ចំពោះខ្លួនឯង និងអ្នកដទៃ។ ប្រការនេះនាំមកភាពស្ងប់ក្នុងចិត្ត (ចិត្តបរិសុទ្ធ) និងអាចជាមូលដ្ឋានឱ្យយើងរកឃើញសច្ចធម៌ក្នុងខ្លួនដែលជាទិសដៅចំបងនៃការប្រតិបត្តិធម៌ ។

៣- ពុំយកឬប៉ះពាល់ (Non-stealing) របស់ណាពុំមែនជារបស់ខ្លួន។ ប្រការនេះពុំមែននិយាយយោងដល់តែសម្ភារៈប៉ុណ្ណោះទេ គឺទាំងផ្លូវចិត្តផងដែរ។ តួយ៉ាងពុំគួរដណ្តើមយកគុណសម្បត្តិឬកិត្តិយសដែលអ្នកដទៃគេសំរេចបានឡើយ ។

៤- ព្រហ្មចរិយា (Brahmacharya) ពុំប្រព្រឹត្តកាមខុសគន្លងសីលធម៌ ដូចជាការថែរក្សាភាពស្មោះត្រង់ប្តីមួយប្រពន្ធមួយ។ មានន័យមួយទៀតគឺបានដល់ការដកលំខ្លួនឱ្យនៅលីវ(celibacy) ជារឿងដរាបដើម្បីជាប្រយោជន៍ដល់ខ្លួននិងអ្នកដទៃ។ ឧទាហរណ៍ដូចជាការលះបង់របស់ព្រះសង្ឃជាដើម (ក្នុងនេះមានបង្កប់អាថ៌កំបាំងមួយដែលគេពុំសូវឮពីមុនមកនោះ គឺការសំចៃវាំមពលកាមគុណ (sexual energy) សំរាប់មុខសញ្ញាផ្សេងដែលមានគុណប្រយោជន៍ខ្ពស់ជាងការបង្កើតកូនបន្តពូជ) ។ (តទៅលេខក្រោយ)

## ហាងខ្មែរជួសជុលរថយន្ត

**បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ**

## Rathe's Auto Service

State and Emission
Inspaction General
Repairs and Maintenance

MON-SAT, 8:30AM-5:30PM
SUN. EMERGENCY ONLY

- ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
- មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
- មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ
- មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២00៨ ទៅ : - ដូរប្រេងកិរិត ៥ ក្វាត $22
- INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់ -មានជូនប័ណ្ណពិសេសសំរាប់ដូរប្រេងចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
- តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត ។
- ប្តេជ្ញាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ។

ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL : (215) 329-2418
Fax : (215) 329-2419. Rath CELL : (215) 431-6376

## ANGKOR AUTO SERVICE,INC.
## ហាងជួសជុលរថយន្ត "អង្គរ"

Free Estimate

**Auto Body and Maintenance**

**BODY WORKS**
Auto glass and windshields
Auto Frame Straightening and Painting

មានបទពិសោធន៍២0ឆ្នាំ ជាជាងរថយន្តមានសញ្ញាប័ត្រវាយតម្លៃការងារដោយឥតយកថ្លៃ ហើយយើងជួយសន្សំប្រាក់តម្លៃបន្ទុយរបស់អ្នកបានផង យើងផ្តល់សេវាគ្រប់យ៉ាង :

ENGINE AND TRANSIMISSION
SERVICES
State Inspection
Check Engine Light Diagnostic
Timing Belt Services
Complete Tune Up:
-Brake -Muffler -Struts
-Water Pump -A/C
-Bearing Services

From the moment you get into car accident, we will take care of you from towing to calling your insurance, and to get a rental car for you. With Angkor Auto, you can be worried free.

4835 N. 16th Street. Philadelphia, PA 19141
Tel : (215) 455-7810 / Ricky : (215) 485-1425

តមកទំព័រទី ០១

# ចូលឆ្នាំចិនឆ្នាំថ្មីនេះ ធ្វើយ៉ាងណា...

តាមសៀវភៅប្រវត្តិខ្លះបាននិយាយថា នាសម័យកាលណោះខុងជឺបានបង្ហាត់បង្ហាញប្រជាជនឱ្យស្គាល់ពីគុណធម៌ សីលធម៌ និងការតបស្នងសងគុណធ្វើឱ្យជីវភាពជាតិមានសណ្តាប់ធ្នាប់ល្អ ហើយជាអ្នកបង្កើតឱ្យមានទំនៀមទម្លាប់សែនព្រេនដូនតារៀងរាល់ឆ្នាំនេះឡើងផងដែរ ។

ដុតក្រដាសសែនក្នុងពិធីចូលឆ្នាំចិន

លោតម៉ុងសាយមុនផ្ទះនៅសិរីសូរិយ៍

**-អំពីជំនឿផ្សេងៗរបស់បងប្អូនជនជាតិចិន :**

ក្នុងពិធីបុណ្យចូលឆ្នាំចិនឬក៏ពិធីផ្សេងៗជាជំនឿរបស់បងប្អូនជាប់សែចិន មានការគោរពប្រណិប័តន៍នូវជំនឿផ្សេងៗជាច្រើនក្នុងនោះ មានការបិទយ័ន្តផ្ទះមានការដុតធាវីមានការលោតម៉ុងសាយ មានការសែនព្រេន ការដុតក្រដាស ដុតធូបនៅព្រះវិហារ ការនាំយកអំពៅខ្ចៅ និងស្លឹកម្បែន និងការតាំងផ្កាអង្គាសីលក្នុងផ្ទះជាដើម ។ល។

**-ជំនឿ និងព្រណមក្នុងថ្ងៃបុណ្យចូលឆ្នាំចិន**

តាមប្រវត្តិសាស្ត្រជនជាតិចិនមានជំនឿលើការគោរពបុណ្យចូលឆ្នាំថ្មីយ៉ាងកប់ជ្រៅ។ គេមានព្រណមជាច្រើននៅក្នុងអំឡុងចូលឆ្នាំបីថ្ងៃ ជាពិសេសថ្ងៃទី១ ឬហៅថា "ឈឺអិច" ។ ក្នុងរយៈពេលពាថ្ងៃនេះ គេចាត់ទុកជាថ្ងៃពិសេសបំផុត ដែលមិនត្រូវធ្វើអ្វីល្អក់កករនាំឱ្យប៉ះពាល់ដល់មង្គលឬដល់ឆ្នាំថ្មីឡើយ។ គេត្រូវធ្វើឱ្យសប្បាយនាំសិរីសួស្តីចូលខ្លួន និងក្រុមគ្រួសារ ។

**- ព្រណមមិនយ៉**

ក្នុងអំឡុងបុណ្យចូលឆ្នាំថ្មីជនជាតិចិនមានព្រណមមិនឱ្យកើតរឿងយំសោកសៅ ពីព្រោះវាអាចនាំមកនូវរឿងអពមង្គលដល់ឆ្នាំថ្មី រហូតពេញមួយឆ្នាំ។ ព្រណមនេះសូម្បីតែកូនចៅដែល រឹងរូសក៏ឪពុកម្តាយ ឬមនុស្សចាស់មិនវាយប្រៀនប្រដៅដែរ គឺអត់ទ្រាំរហូតចប់បុណ្យចូលឆ្នាំថ្មីសិន ។

**-តែងខ្លួនស្អាត ប៉ុន្តែមិនគួរកក់សក់**

ការស្លៀកពាក់ខោអាវថ្មី និងខ្លួនស្អាតបាតជារឿងសំខាន់បំផុតសម្រាប់មនុស្សគ្រប់រូបក្នុងការទទួលឆ្នាំថ្មី ។ ទោះបីយ៉ាងណាក្នុងអំឡុងពេលនេះ គេមានព្រណមមួយគឺហាមកក់សក់ក្បាល ប៉ុន្តែកន្លែងដទៃទៀតអាចធ្វើការសម្អាតបានធម្មតាពីព្រោះថា ការកក់សក់គេមានជំនឿថាហាក់បីដូចជាការលាងជម្រះជោគសំណាងចេញពីខ្លួនដូច្នេះដែរ។ ចំពោះសម្លៀកបំពាក់ពណ៌ក្រហមជាទីពេញនិយមបំផុត ដែលគេប្រើសម្រាប់ស្លៀកពាក់ក្នុងអំឡុងចូលឆ្នាំថ្មី។ ពណ៌នេះគេចាត់ទុកជាពណ៌ង៉ូវហេងនាំជោគលាភ និងសិរីសួស្តី។ សម្រាប់ក្មេង ឬមនុស្សនៅលីវ គេតែងឱ្យ"អាំងប៉ាវ" ដែលជាកញ្ចប់លុយពណ៌ក្រហម ព្រមទាំងក្រដាសប្រាក់ថ្មី១ ដើម្បីទទួលជោគលាភផង ។

**-ពិភាក្សាជាមួយ "ចិនសែ" ពេលដើរចេញពីផ្ទះ**

ជនជាតិចិនខ្លះដែលមានជំនឿខ្លាំងពេលចេញដំណើរកម្សាន្តពីផ្ទះអាចមានរហូតអញ្ជើញគ្រូទាយ ដើម្បីរកពេលវេលាល្អសម្រាប់ចាកចេញពីផ្ទះទៀតផង។ ថ្ងៃទីមួយដែលចាកចេញពីផ្ទះពេលបានជួបប្រទះអ្វីចាប់អារម្មណ៍អាចនាំមកនូវការកំណត់ជោគវាសនាពេញអស់មួយឆ្នាំបាន។ ជោគសំណាងដែលគេចង់ជួបបំផុត គឺបានឮបក្សីស្រែកច្រៀង ឬឃើញបក្សីពណ៌ក្រហមដែលចាត់ទុកថានាំមកនូវជោគសំណាងល្អ ។

**- ហាមចូលបន្ទប់របស់អ្នកដទៃ**

ការចូលទៅរកនរណាម្នាក់ក្នុងបន្ទប់ដេករបស់គេក្នុងថ្ងៃបុណ្យចូលឆ្នាំថ្មីចាត់ទុកថា ជាជោគសំណាងអាក្រក់។ ទោះបីអ្នកមានភោគជំងឺដែលត្រូវចូលទៅសួរសុខទុក្ខក៏ចាំបាច់ត្រូវចេញមកអង្គុយក្នុងបន្ទប់ទទួលភ្ញៀវដែរ។

**-មិនគួរប្រើកាំបិតឬកន្ត្រៃក្នុងថ្ងៃបុណ្យចូល ឆ្នាំថ្មី**

ព្រោះគេមានជំនឿថា ការកាត់ជោគលាភ ហើយបើមានមុតដៃជើងផង គឺកាន់តែជួបរឿងអាក្រក់ថែមទៀត។

**- មិនឱ្យបែកចាន-កែវ :** ក្នុងថ្ងៃនេះគេមានការប្រយ័ត្នប្រយែងចំពោះការកាន់ចាន-កែវ ព្រោះបើមានបង្កឱ្យប្រេះស្រាំ ឬធ្លាក់បែកជាការនាំឱ្យបាត់បង់ជោគលាភ ហើយជីវិតក្នុងឆ្នាំនោះនឹងជួបតែរឿង ប្រេះឆាពុំសូវមានសេចក្តីសុខឡើយ។ សូមជូនពរឆ្នាំថ្មីឱ្យគ្រប់ៗរូប និងគ្រប់ក្រុមគ្រួសារមានសុភមង្គលល្អ និងសំបូរសប្បាយ ! ॥

(Continued from page 01 )

## THE SOCIO-ECONOMIC...

Southeast Asians has only 9 board membes. Six board members resigned due to their personal reasons.

Additionally per Ms. Phivilay, Socio-Economic Development Center process for choosing board members is consist of 2 representatives each of the 4 Mutual Assistance Associations, Cambodian Society of Rhode Island, Inc., Hmong United Association Association of Rhode Island, Inc., Laotian Association of Rhode Island, Inc.; and Vietnamese Society of Rhode island, inc.. The rest of Board members are choosen by the existing board members.

Socio-Economic Development Center formed to serve people from all national with program such as

- Youth And Family Development Services
- Victims of Crime Assistance (VOCA)
- Substance Abuse Prevention
- Meals on Wheels
- ESL Class
- Citizenship Class
- GED Class
- Health Advocacy
- Volunteer Income Tax Assistance (VITA)
- Family Support Program
- Voter Registration
- Language Bank

There are program assisting the elderly and many more with free of charge.

So, should anyone has any question or require additional information with the above services please call 401-274-8811 or directly go to the office at 270 Elmwood Avenue, Providence, Rhode Island 02907.


# ការិយាល័យច្បាប់

## ERIK B.JENSEN P.C

*A Profesional Corporation*

**We Handle All INJURY CASES**

- Auto/Bus/Train/Motorcycle
- Slip and Fall / Workplace Accidents
- Medical Malpractice
- Nursing Home Neglect
- Dog Bites / Wrongful Death

**Criminal Defense—DUI**

Adult & Juvenile
Felonies / Misdemeanors / Drug Offenses
Weapons Charges / Murder / Manslaughter
Robbery / Burglary / Theft / Rape / Child Abuse
Drunk Driving / Traffic Violations

**BANKRUPTCY**

Sheriff Sales / Foreclosures / Repossessions
Credit Repairs / Tax Liens

**FAMILY**

Divorce / Support
Alimony / Child Custody
Protection From Abuse
Visitation / Adoptions

**BUSINESS**

Contracts / Negotiations
Litigation
Start-ups / Financing
Collections

**REAL ESTATE**

Commercial – Residential
Buying / Selling
Settlements / Closings

**TAX PROBLEM**

IRS Disputes / Tax Fraud
Audits / Liens / Levies
Tax & Estate Planning

Wills, Estates & Trusts Social Security

FREE Consultation ERIK B. JENSEN, P.C. Attorneys At Law

215-546-4700 24 HOUR AVAILABILITY 800-522-6606
1528 Walnut St., Suite 1401 Philadelphia

មានអ្នកបកប្រែភាសាខ្មែរ

Rely On Over
26 Years Of Experience

WWW.ERIKJENSENLAW.COM

we have Khmer staff

Voun Lay, BS
Marketing Coordinator
267-738-7006

ទស្សន៍ទាយជោគជាតាសី

# ជោគជតារាសីលោកអ្នកថ្ងៃទី ១១-២៤ ខែកុម្ភៈ ឆ្នាំ២០១១

**ឆ្នាំជូត : (ពង្សទេព្តាប្រុស ធាតុទឹក)**

*រាសីលោកអ្នកផ្តើជំនួសត្រដែត។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់។ ក្នុងរយៈពេលនេះ ថ្វីត្បិតតែការងាររកស៊ីរបស់លោកអ្នកបានជួបនឹងគូប្រជែងជើងខ្លាំងយ៉ាងណាក្តីក៏មិនភ័យព្រួយអ្វីដែរ ព្រោះលោកអ្នកមានប្រៀបឈ្នះជាប់ជានិច្ច។ ចំពោះកំលោះក្រមុំក្នុងរយៈពេលនេះអាចទាក់ទងគ្នានឹងបានក្លាយជាគូស្នេហ៍ដ៏ប្រពៃមួយគូ ៕*

**ឆ្នាំឆ្លូវ : ( ពង្សមនុស្សប្រុស ធាតុដី )**

*រាសីលោកអ្នកល្អជាមធ្យម។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ។ ក្នុងរយៈពេលនេះ ថ្វីត្បិតតែមានភាគដលចំណូលហូរចូលច្រើនគួរសមក្តី តែពុំមានសល់អ្វីជាដុំកំភួនឡើយ ព្រោះចាយវាយខ្ជះខ្ជាយខ្លាំងពេក ហើយក៏មិនខុសពីទូកធំក្តោងធំនោះដែរ ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះទាល់តែចេះអត់ឱនឲ្យគ្នាទៅវិញទៅមកទើបមិនអាចប្រេះឆាគ្នាបាន ៕*

**ឆ្នាំខាល : ( ពង្សយក្សស្រី ធាតុឈើ )**

*រាសីលោកអ្នកផ្តើជំនួសត្រដែត។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អណាស់។ ក្នុងរយៈពេលនេះលោកអ្នកមានអារម្មណ៍ក្តីថ្លាគំនិតប្រាជ្ញាឈ្លាសវៃ ទោះបានប្រកបកិច្ចការងារអ្វី ៗក៏ដោយក៏អាចទទួលបានផលសម្រេចសមតាមបំណងប្រាថ្នាទាំងអស់ តែចូរកុំមានចិត្តលោភលន់ឲ្យសោះ ព្រោះការលោភលន់នាំមកនូវក្តីវិនាសអន្តរាយ។ គូស្នេហ៍មានភាពល្អកល្ហែនយល់ចិត្តគ្នាល្អណាស់៕*

**ឆ្នាំថោះ : ( ពង្សមនុស្សស្រី ធាតុឈើ )**

*រាសីលោកអ្នកផ្តើជំនួសត្រដែត។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់។ ក្នុងរយៈពេលនេះទោះដាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយ គឺរមែងតែងតែបានទទួលផលសម្រេចសមតាមបំណងប្រាថ្នាទាំងអស់។ ក្នុងរយៈពេលនេះបុរសត្រូវប្រយ័ត្នចំពោះមនុស្សស្រីដែលមានសម្តីផ្អែមអាចលោយទ្រព្យធាប់។ គូស្នេហ៍ប្រកបតែសេចក្តីសុខក្សេមក្សាន្ត ៕*

**ឆ្នាំរោង : (ពង្សទេព្តាប្រុស ធាតុមាស)**

*រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ។ ក្នុងរយៈពេលនេះអ្វី ៗច្រើនមានការប្រែប្រួលពុំទៀងទាត់ឡើយ។ ដូច្នេះបើលោកអ្នកមានទិញលក់ដីធ្លីផ្ទះ ឬវត្ថុមានតម្លៃផ្សេង។ ចូរធ្វើលិខិតស្នាមដោយមានបុះហត្ថលេខា ឬផ្តិតស្នាមមេដៃឲ្យបានត្រឹមត្រូវទើបទៅថ្ងៃមុខពុំមានបញ្ហាចោទឡើង ។ គូស្នេហ៍ប្រកបតែសេចក្តីសុខក្សេមក្សាន្ត ៕*

**ឆ្នាំម្សាញ់ : (ពង្សមនុស្សប្រុស ធាតុភ្លើង)**

*រាសីលោកអ្នកល្អជាមធ្យម។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ។ ក្នុងរយៈពេលនេះអ្វី ៗច្រើនមានការប្រែប្រួលពុំទៀងទាត់ឡើយ ដូច្នេះបើលោកអ្នកមានលក់ដីធ្លីផ្ទះសម្បែង ឬវត្ថុមានតម្លៃផ្សេង។ ចូរធ្វើលិខិតស្នាមជាលាយលក្ខណ៍អក្សរដោយមានបុះហត្ថលេខា ឬផ្តិតស្នាមមេដៃឲ្យបានត្រឹមត្រូវទើបទៅថ្ងៃមុខពុំមានបញ្ហាចោទឡើង ។ ចំពោះគូស្នេហ៍មានភាពស្និទ្ធស្នាលដូចប្រក្រតី៕*

**ឆ្នាំមមី : (ពង្សទេព្តាស្រី ធាតុភ្លើង)**

*រាសីលោកអ្នកស្រុកចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបនឹងរឿងរកាំរកូសច្រើន។ ក្នុងរយៈពេលនេះ ទោះដាលោកអ្នកបានប្រកបការងារអ្វីក៏ដោយ ចូររៀបចំគម្រោងដែនការជាមុនទើបពុំមានការថ្ងោះឆ្ងោយ។ ក្រៅពីនោះបើមានរឿងឈ្លោះវិវាទកើតឡើង ចូរចេះអត់ធ្មត់ និងរម្ងាប់ចិត្តឲ្យបានត្រជាក់ទើបរឿងក្តៅមិនអាចក្លាយជារឿងធំបាន។ គូស្នេហ៍ក្នុងរយៈពេលនេះច្រើនពាក់មុខឲយក្សដាក់គ្នា៕*

**ឆ្នាំមមែ : (ពង្សទេព្តាស្រី ធាតុមាស)**

*រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹម ៗ។ ក្នុងរយៈពេលនេះដោយមំនាយទាយថា អាចបង់ខាតច្រញ្ជះ ៗ។នោះ ដូច្នេះចូរកុំឲ្យគេខ្ចីរបស់របរមានតម្លៃឲ្យសោះ ព្រោះកាលបើបានធ្លាក់ដល់ដៃគេហើយ គឺគ្មានថ្ងៃបានវិលត្រឡប់វិញឡើយ ។ ចំពោះ គូស្វាមីភរិយាក្នុងរយៈពេលនេះមានផលប៉ះទង្គិចគ្នាបន្តិចបន្តួច ៕*

**ឆ្នាំវក : (ពង្សយក្សប្រុស ធាតុដែក)**

*រាសីលោកអ្នកស្រុកចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបរឿងរកាំរកូសច្រើន ។ ក្នុងរយៈពេលនេះ បើមានរឿងឈ្លោះវិវាទកើតឡើង ចូរចេះអត់ធ្មត់ និងរម្ងាប់ចិត្តឲ្យបានត្រជាក់។ ចំពោះស្ត្រីកេរក្នុងរយៈពេលនេះមិនត្រូវនិយាយស្តីបំប៉ាច់បំប៉ោចឥតបានការច្រើនពេកទេ ព្រោះរឿងរ៉ាវផ្សេង ៗអាចកើតចេញពីពាក្យសម្តី ។ ចំពោះគូស្វាមីភរិយាចូរប្រយ័ត្នប្រយែងក្រែងមានអ្នកទីបីចូលជ្រៀតជ្រែក ៕*

**ឆ្នាំរកា : (ពង្សយក្សប្រុស ធាតុដែក)**

*រាសីលោកអ្នកល្អជាមធ្យម។ រាល់កិច្ចការងាររកស៊ីជួញដូរកាក់កបល្អគ្រាន់បើ។ ក្នុងរយៈពេលនេះ ទោះដាលោកអ្នកបានប្រកបការងារអ្វីក៏ដោយ ចូរកុំធ្វេសប្រហែសឲ្យសោះ ជាពិសេសចំពោះអាជីវករអ្នករកស៊ីលក់ដូរមុនទឹងប្រគល់ ឬទទួលនូវមុខទំនិញសព្វសាររពើ ចូរចេះពិនិត្យមើលគុណភាព ឱនរាប់ចំនួនឲ្យបានត្រឹមត្រូវ។ ចំពោះគូស្វាមីភរិយា ចូរប្រយ័ត្នអ្នកក្រៅមកញុះញង់ ៕*

**ឆ្នាំច : ( ពង្សយក្សស្រី ធាតុដី )**

*រាសីលោកអ្នកល្អមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ។ ក្នុងរយៈពេលនេះថ្វីត្បិតតែការងាររកស៊ីអាចរើប ។បន្តិចឡើងវិញក្តី តែអ្វីដែលលោកអ្នកគួរប្រយ័ត្នប្រយែងនោះ គឺនឹងមានមនុស្សសម្តីផ្អែមបំផ្លាចកច្រាស់តាមគ្រប់រូបភាព ដូច្នេះទាំងបុរសស្ត្រី គឺមិនត្រូវជាប់ត្រចៀកទន់ជឿទុកចិត្តគេពេកទេ។ គូស្នេហ៍ក្នុងរយៈពេលនេះប្រកបតែសេចក្តីសុខនឹងគ្នា ៕*

**ឆ្នាំកុរ : (ពង្សមនុស្សស្រី ធាតុទឹក)**

*រាសីលោកអ្នកល្អជាមធ្យម។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ។ ក្នុងរយៈពេលនេះ ទោះដាលោកអ្នកបានប្រកបការងារអ្វីក៏ដោយ គឺអាចទទួលបានផលសម្រេចត្រឹមតែពាក់កណ្តាលប៉ុណ្ណោះ ដូច្នេះលោកអ្នកមិនត្រូវហ៊ានប្រថុយប្រថានបណ្តាក់ទុនរកស៊ីដោយទ្រង់ទ្រាយធំឡើយ ។ ចំពោះគូស្នេហ៍មានភាពស្និទ្ធស្នាលដូចសព្វមួយដង ៕*

## តមកចំព័រទី ០១

## មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍...

អ្នកស្រីបានបន្ថែមទៀតថា : មជ្ឈមណ្ឌលនេះពុំមានការបោះឆ្នោតសំរាប់ជ្រើសរើសសមាជិកគណៈកម្មការនោះទេ គឺបេក្ខភាពគណៈកម្មការទាំងអស់ត្រូវបានខាងមជ្ឈមណ្ឌលធ្វើការស្នើសុំពីសមាជិក ប្រជាជាតិអាស៊ីនីមួយៗ នៅក្នុងរដ្ឋរ៉ូដនៃឡិន្ត មានដូចជា: ២រូបមកពីសមាគមខ្មែរ ២រូបមកពីសមាគមលាវ ២រូបមកពីសមាគមម៉ុង និង២រូបមកពីសមគមវៀតណាមជាដើម។ មជ្ឈមណ្ឌលនេះបង្កើតឡើងសំរាបជួយប្រជាពលរដ្ឋទូទៅដូចជា :

- សេវាអភិវឌ្ឍន៍យុវជន និងគ្រួសារ
- ជំនួយដល់អ្នករងគ្រោះដោយអំពើឧក្រិដ្ឋ
- ការពារកុំឲ្យប្រើគ្រឿងញៀន
- ថ្នាក់បង្រៀនភាសាខ្មែរ
- ថ្នាក់បង្រៀនចូលសញ្ជាតិ
- ថ្នាក់បង្រៀនយកឌីប្លូម
- ណែនាំខាងសុខភាព
- ស្ម័គ្រចិត្តជួយធ្វើតាក់
- កម្មវិធីគាំទ្រគ្រួសារ
- ចុះឈ្មោះបោះឆ្នោត
- ភាសាធានាគារ

នៅមានកម្មវិធីសម្រាប់ជួយមនុស្សចាស់និងកម្មវិធីមួយចំនួនទៀត សំរាប់បំរើសហគមន៍ដោយឥតគិតកម្រៃ។

ហើយកម្មវិធីទាំងអស់នេះ គឺទទួលបំរើដោយឥតគិតថ្លៃ។ ដូច្នេះបងប្អូនដែលមានចំណាប់អារម្មណ៍នូវកម្មវិធីខាងលើ ឬក៏មានចំងល់អ្វីបន្ថែមបងប្អូនអាចទាក់ទងមកទូរស័ព្ទលេខ: ៤០១ ២៧៤ ៨៨១១ ឬក៏ អាចអញ្ជើញទៅកាន់ការិយាល័យផ្ទាល់ ដែលមានអាស័យដ្ឋាននៅ 270 Elmwood Ave. Providence, RI 02907 យើងខ្ញុំរីករាយនឹងបំរើជូនបងប្អូន ៕

# វត្តព្រះពុទ្ធប្រទានពរបន្តក្តីនៅតុលាការ

**ហ្វីឡាដែលហ្វៀ :** គណៈកម្មការវត្តព្រះពុទ្ធប្រទានពរ និងលោក ស៊ុម សាក់ អតីតចៅអធិការដែលបានចូលទៅសាលាដោះស្រាយវិវាទដោយមេធាវីជាតំណាងរឿងៗខ្លួន ដើមបណ្តឹងគឺគណៈកម្មាធិការវត្ត បានចេញដីការអញ្ជើញឱ្យលោក ស៊ុម សាក់ ចាកចេញពីបរិវេណវត្ត ដែលលោកយកបន្ទប់មួយនៅតាំងតែលោកនៅបួសនៅឡើយ រីឯ ស៊ុម សាក់ មិនបានចាកចេញដូចពាក្យរបស់ដីការនោះឡើយ ដោយសំអាងថា លោកនៅមានសិទ្ធិជាអ្នកបង្កើតវត្តអារ៉ាមនៅឡើង ហើយជាពិសេស ពុំមានលិខិតណាមួយដែលថាលោកឈប់ធ្វើជាចៅអធិការ និងជាប្រធានវត្តនៅឡើយទេ។

លោក ត្រែ ហ៊ិល គណៈកម្មាធិការវត្តព្រះពុទ្ធប្រទានពរនៅឯសាលាដោះស្រាយវិវាទ

កាលពីថ្ងៃទី៣ ខែកុម្ភៈកន្លងទៅនៅសាលាចរចាវិវាទនោះ មេធាវីខាងគណៈកម្មាធិការវត្ត បាននិយាយប្រាប់កូនក្តីរបស់ខ្លួនថាលោក ស៊ុម សាក់ បានទារថ្លៃ ដែលលោកបានចំណាយថវិកាផ្ទាល់ ដើម្បីទិញវត្តព្រះពុទ្ធប្រទានពរនោះចំនួន៨ម៉ឺន៥ពាន់ដុល្លារ។ រីឯគណៈកម្មាធិការតំណាងដោយព្រះគ្រូចៅអធិការវត្ត សុទ្ធ សារិម និងលោក ត្រែហ៊ិល បាននិយាយថា គណៈកម្មាធិការវត្តមិនដែលជំពាក់ ស៊ុម សាក់ ច្រើនដល់ម្តឹងទេ ជាពិសេសគណៈកម្មាធិការវត្ត បានប្រមូលបច្ច័យបាន ហើយជូនថ្លៃទិញផ្ទះនោះជាទៀតទាត់ទៅ ស៊ុម សាក់ ពេលនោះជាចៅអធិការតែបែរជាលុយនោះ ពុំបានទៅទូទាត់ថ្លៃទិញផ្ទះទៅវិញ។

ករណីនេះនឹងបណ្តាលឱ្យមានកិច្ចចរចាម្តងទៀត ដើម្បីសម្តែងពីគោលជំហររបស់គណៈកម្មាធិការវត្តនៅបីសប្តាហ៍ខាងមុខ ហើយបន្ទាប់ពីនោះទៅ បើមិនបានសម្រេចគេនឹងទៅសាលាជំម្រះក្តីជាបន្តទៅទៀត ៕

*-ខ្មែរប៉ុស្តិ៍-*




GET YOUR MONEY FAST!
24 HR FAST REFUNDS
e-File: States & Federal

NOEL TAX CONSULTANTS
6141 Lindo Stn Apt
Philadelphia, PA 19111
TEL (215)- 821-2443
LOW FEES BETTER SERVICE
PICKUP CHECK OR DIRECT DEPOSIT
GET YOUR TAXES DONE @ NOEL'S AND WIN A 50-INCH PLASMA TV
www.noeltax.com
AQUI SE HABLA ESPANOL
DESIGNED BY P GRAPHICS 215-668-5676


តមកពីទំព័រទី ០៩

## សូមកុំជេរនាយករដ្ឋមន្ត្រីថា...

ម្យ៉ាងទៀតពាក្យពេចន៍ថ្លែងព្រមានដល់សភាតំណាងប្រជាពលរដ្ឋ កុំឱ្យជេរថា អាក្បត់ជាតិនោះ ថែមទាំងមានបង្កប់ពិសពុលមាន អត្ថន័យជាពាក្យគម្រាមកំហែងឱ្យខ្លាច និងគំនុំគំគួន ចងអាឃាត ជាមួយជនជាតិខ្មែរ គ្មាឯងថាត្រូវតែចោទប្រកាន់ឱ្យមានជាប់ទោសទោះបីអស់លោកទាំងនោះ មានអភ័យឯកសិទ្ធិ ឱ្អភ័យឯកសិទ្ធិ ក៏ត្រូវតែ ដាក់សិនហើយពីព្រោះលោកជាអ្នកជាប់ឆ្នោត មានសម្លេងបោះឆ្នោតជូនពីប្រជាពលរដ្ឋ អីចឹងត្រូវធ្វើអ្នកដទៃ និងបរទេសកុំលូកលាន់ ។

ពាក្យទាំងនេះ បានបញ្ជាក់ឱ្យដឹងថា ជាចេតនាប៉ុនប៉ងត្រូវតែធ្វើទុក្ខទោសដល់អស់សភាតំណាងប្រជាពលរដ្ឋ ដែលសុទ្ធតែមានសិទ្ធិអំណាចជួយការពារផលប្រយោជន៍ប្រទេស និងប្រជាពលរដ្ឋឱ្យសមស្រប់ទៅតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស គតិយុត្តិធម៌ និងមានបុព្វសិទ្ធិជាប្រជាពលរដ្ឋ ត្រូវតែមានសិទ្ធិសេរីភាពតាមច្បាប់រដ្ឋធម្មនុញ្ញ និងនិតិរដ្ឋគ្រប់ប្រការ ។

លោកនាយករដ្ឋមន្ត្រី ហ៊ុនសែន និងមន្ត្រីគ្រប់តំណែងត្រូវតែកែសម្រួលប្រព័ន្ធនយោបាយដឹកនាំឱ្យបានសស្រេចសមស្របទៅតាមឆន្ទៈប្រជាពលរដ្ឋខ្មែរ និងទៅតាមគតិយុត្តិធម៌ គោរពច្បាប់និតិរដ្ឋ និងបង្កើតបរិយាកាសល្អប្រសើរក្នុងការអនុវត្តន៍កិច្ចការក្នុងឧត្តមគតិ មនសិការ សតិស្មារតីជាតិនិយមពិតប្រាកដ ដោយកុំយកជាតិខ្មែរគ្នាឯងជាខ្មាំងសត្រូវ ត្រូវទុកជនជាតិខ្មែរទាំងអស់ជាខ្មែរតែ១ មានបេះដូងតែ១ មានព្រលឹងជាខ្មែរតែ១ មានសតិសម្បជញ្ញៈវិចារណញ្ញាណជាខ្មែរតែ១ ក្នុងហ៊ានៈជាខ្មែរម្ចាស់ប្រទេស និងជាម្ចាស់លើអ្វី១ទាំងអស់ ជារបស់ជាតិខ្មែរ ឱ្យបានគង់វង្សស្ថិតស្ថេរចេរកាលជានិរន្តរ៍តទៅ ។


Khmer Post Classified

To Place an ad, call (267) 253-3947
e-mail KhmerPostUSA@gmail.com

ខេនី ត្រូវេទមន្តដោយសម្មាធិ

មើលជម្ងឺនានា, ដោះមន្តស្នេហ៍, រំដោះគ្រោះ, ជួយគ្រួសារបែកបាក់, មើលមុខរបររកស៊ី, ហុងស៊ុយ, ធ្វើយ័ន្តការពារខ្លួន។
ចេះមន្តអាគមតាមរបៀប ចិន, យួន, ចាម ។
បើចង់ដឹងបន្ថែមសូមទំនាក់ទំនងតាមរយៈទូរស័ព្ទ:
(540) 397-2603 ខ្ញុំឈ្មោះ "KENNY"

ធីណា TINA
អ្នកទាយជោគជតា និង អ្នកណែនាំ

TINA PSYCHIC READER & ADVISOR
Invites you to have a Clairvoyant experience where she offers tarot card readings, palmstry, companion reading or simply find out your spiritual color of life.
I have successfully guided people through their confusing circles of life, such as love, business or simply to find peace within their selves.
Specializing In:
• Clairvoyant & Crystal Readings • Tarot Cards
• Palmistry • Meditation Therapy • Aura Cleansing
• Soulmate Consultations
267-444-3924
Part of Center City
711 Walnut St. Phila., PA
Mention this ad for a $5 OFF Special

Yoo's Auto Service and Collision
យូ បំរើសេវារថយន្ត
និងរថយន្តគ្រោះថ្នាក់ប៉ះទង្គិច

FREE ESTIMATES
យើងនឹងជួសជុលរថយន្តដ៏មានតម្លៃរបស់លោកអ្នក ឱ្យបានប្រសើរបំផុត តាមតែយើងធ្វើបាន ដើម្បីសុវត្ថិភាពលោកអ្នក មិនឱ្យខុសចិត្តឡើយ ។

189 W. Duncannon Ave. Phila., PA 19120

COUPON
$10 OFF TOWARD EMISSION AND STATE INSPECTION
Khmer Post

ពោធជាងម៉ាស៊ីន
Check Engine Light Diagnostic
Electronic Wheel Alignment
Certified Enhanced Emission Inspection & Repairs
Muffler & More

ពោធជុំសជុលតួរថយន្ត
Expert Body Work
Fender & Paint Work
Frame Straightening
Insurance Specialists

ទូរស័ព្ទកេ SAM 215-457-7777 ឬ 215-457-7779, Fax-215-457-7475

ដំបូងបង្អស់ និងមានតែមួយនៅហ្វីឡាដែលហ្នឹ

**"ហាងកុំព្យូទ័រដែលគេប្រើរួចហើយ"**

ធ្វើប្រព័ន្ធកុំព្យូទ័រ * កុំព្យូទ័រសំរាប់ធ្វើដំណើរ * គ្រឿងបន្លាស់ * ជួសជុលកុំព្យូទ័រ *

***Philadelphia's First and Only***

**Computer Thrift Store**

Computer Systems * Laptops * Accessories * Computer Repair *

**Monday-Friday 10am-6pm. Saturday 10am-40pm**

បើពុំមានថវិការគ្រប់គ្រាន់សំរាប់ទិញកុំព្យូទ័រថ្មី ហេតុអ្វីក៏មិនរកកុំព្យូទ័រដែលគេធ្លាប់ប្រើ តែអាចធានាគុណភាពបាន ! សូមអញ្ជើញមកមើលសម្ភារៈដែលលោកអ្នកត្រូវការ នៅអាស័យដ្ឋាន ខាងក្រោម :

**Nonprofit Technology Resources**

**1524 Brandywine Street. 1 Block North of 15th & Spring Garden St.**

***We Provide Free Parking! We accept computer donations (Tax Write-Off)***

**215-564-6686**



# ខ្មែរប៊ុស្ស.រ.អា

ឱកាសចូលឆ្នាំថ្មីមកដល់ហើយ ! លោកអ្នកអាចបញ្ជូនសារជាសាធារណៈ ជាការជូរពរតិមាន ជាការស្វែងរក ជាពិសេសប្រើឱកាសដ៏សំខាន់នេះ សំរាប់ជូនពរសព្ទសាធុការ ដល់ញាតិមិត្ត បូកំភ្លៀវដ៏ល្អដែលធ្លាប់មានការប្រាស្រ័យទាក់ទងជាមួយកិច្ចការ ឬពាណិជ្ជកម្មលោកអ្នក ។ ការថែរក្សាអារម្មណ៍ល្អរបស់ចាស់ទុំ-មិត្តភ័ក្ត្រ ឬភ្ញៀវពិសេស គឺជាការបង្កើនគុណសម្បត្តិខ្ពស់សំរាប់អនាគតដ៏ប្រសើរនៃជីវិត និងមុខរបរមិនខុសចិត្តឡើយ ។

"ខ្មែរប៊ុស្ស" ត្រូវការជ្រើសរើសបុគ្គលិកផ្នែកទីផ្សារ នៅតំបន់ឡូវែល និងប្រវិនិន មានកំរៃខ្ពស់ បើមានចំណាប់អារម្មណ៍សូមទំនាក់ទំនងមក :

សុបិន : (267) 253-3947, សែម : (781) 244-0522



# SAIGON PLAZA

ជាហាងថ្មីស្រឡាង ស្ថិតនៅញូជើស៊ីខាងត្បូង-យើងមានរបស់គ្រប់យ៉ាងដែលលោកអ្នកត្រូវការ នៅមិនឆ្ងាយពីផ្ទះ

## 新城超級市場
## SUNSENG SUPERMARKET

5201 Kaighns Ave (Route 38 W ) Pennsauken, NJ 08109

Tel : (856) 663-2238

- បន្លែបង្កាស្រស់ៗមកពីចំការ
- គ្រឿងសមុទ្រ -ត្រីរស់គ្រប់យ៉ាងដែលលោកអ្នកចូលចិត្ត
- សាច់ : មានសាច់គ្រប់មុខ សាច់ជ្រូក-មាន់-គោ-ចៀម... ។ល។

- នៅបរិវេណជ្រលងហ្សា មានពាណិជ្ជកម្មផ្សេងៗទៀត ដូចជា : ការ៉ហ្វេ ទូឡាន -ហ៊ើ៣៨- ABC ប្តូរលុយ -លក់សំបុត្រយន្តហោះ មានហាងកាត់និងអ៊ុតសក់ -JB ក្រុមហ៊ុនអាស៊ាន -ក្រុមហ៊ុនធ្វើតាក់ពន្ធដារ
- បើកទ្វារមួយអាទិត្យ : ៧ថ្ងៃ ពីម៉ោង 8:00 AM ដល់ 9:00 PM
- បុគ្គលិកនៅបំរើយ៉ាងរាក់ទាក់ ដើម្បីបំពេញបំណងលោកអ្នក
- យើងទទួល Credit Card -Food Stamp-EBT- Family Card

នៅមានបន្ទប់
សំរាប់ធ្វើការិយាល័យ
សំរាប់ជួល

# ស្ត្រីខ្មែរដំបូងបង្អស់ដែលបានធ្វើដំណើរពីប្រទេសចាំងមកភ្នំពេញតាមផ្លូវគោក

(តពីលេខមុន)

ដោយ : ពិន នារីពិទូ

•ដោយសារមានអន្តរាគមន៍ ពីស្ថានទូតបារាំងប្រចាំនៅប្រទេសវៀតណាមតំណាងស្ថានកុងស៊ុលអ្នកស្រី Agnes David បានជួនដំណើរឯកសារព្រមព្រៀងពីអាជ្ញាធរវៀតណាមផ្តល់សិទ្ធិក្នុងការបើកបរយានយន្តនៅក្នុងប្រទេសវៀតណាម បានពួកគាត់មិនបង្អង់យូរក៏ប្រញាប់ប្រញាល់មកខេត្ត Lang Song ដែលនៅតាមព្រំប្រទល់។ បន្ទាប់ពីបំពេញឯកសារ និងត្រួតពិនិត្យយានយន្តរួចរាល់ពួកគាត់ជាមួយនឹងអ្នកបើកបរជនជាតិវៀតណាមបាន ធ្វើដំណើរបន្តតាមរថយន្តរបស់ខ្លួនមកទស្សនាទីក្រុងហាណូយ ខេត្ត Ninh Binh ខេត្ត Hue ខេត្ត Hoi Ann ខេត្ត Qui Nhon Nha Trang ខេត្ត Muine ដែលសុទ្ធសឹងជាតំបន់ស្ថិតតាមបណ្តោយឆ្នេរសមុទ្រដ៏ស្រស់ស្អាត និងបន្តមកទីក្រុងប្រជុំជន Ho Chi Minh នៅទីក្រុងហូជីមិញ ពួកគាត់បានជិះរថយន្តក្រុងបន្តមកប្រទេសកម្ពុជា រួមដំណើរជាមួយជនជាតិខ្មែរដែលបានធ្វើកម្មសិក្សានៅប្រទេសវៀតណាមមួយរយៈពេល ហើយត្រូវិលត្រឡប់មកប្រទេសកម្ពុជាវិញ ពួកគាត់ក្នុងការធ្វើដំណើរទៅវិញទៅមក ហើយ Anne និង Jacques បានសន្យាថានឹងរកមធ្យោបាយជួយរំដោះរថយន្តមកវិញ ពីព្រោះឆ្នាំមុនពួកគេបានទទួលនូវសិទ្ធិអនុញ្ញាតឱ្យធ្វើចរាចរណ៍នៅប្រទេសវៀតណាមរួចមក ។ ចំណែកឯមិត្តភ័ក្ត្រដែលនៅប្រទេសបារាំងអ្នកនាង Isabelle បានខិតខំភ្ជាប់ទំនាក់ទំនងពីទីក្រុងប៉ារីស មកស្ថានទូតបារាំង ហើយឯកអគ្គរាជទូតបារាំងនៅហាណូយបានសន្យាថានឹងជួយ ដោះស្រាយក្នុងរឿងនេះដើម្បីសង្គ្រោះរថយន្ត។ នៅទីបំផុតពួកគេបានទទួលសិទ្ធិធ្វើចរាចរណ៍ឆ្លងកាត់ប្រទេសវៀតណាម ដោយជោគជ័យ ។

ពួកគាត់បានចាកចេញពីភ្នំពេញនៅថ្ងៃពុធ ទី១៣ ខែធ្នូ ទៅប្រទេសវៀតណាមម្តងទៀតដើម្បីបន្ត និងបញ្ចប់នូវការធ្វើដំណើរទៅតាមច្បាប់ហើយ ក៏ជាគោលដៅនៃការទៅសង្គ្រោះរថយន្តជាថ្មីម្តងទៀត ។

បានចែករំលែកនូវការសប្បាយជាមួយគ្នាទៅវិញទៅមកព្រមទាំងផ្តល់បទពិសោធន៍ក្នុងការធ្វើដំណើរកន្លងមក។ ហេតុអ្វីបានជាអ្នកអង្គម្ចាស់ខកខានធ្វើដំណើរតាមរថយន្តផ្ទាល់ខ្លួនមកប្រទេសកាន់កម្ពុជា បែរជាត្រូវជិះរថយន្តក្រុងត្រឡប់មកកម្ពុជាវិញ? អ្នកអង្គម្ចាស់ស៊ីលវីយ៉ា បានឆ្លើយប៉ាំភ្លឺថា រថយន្តផ្ទាល់ខ្លួនពេលនោះបានត្រូវអាជ្ញាធរវៀតណាមឃាត់ទុកនៅតាមព្រំដែនអស់មួយខែ បន្ទាប់ពីមានការជួយជ្រោមជ្រែងពីមិត្តភ័ក្ត្ររបស់គាត់បានធ្វើការទំនាក់ទំនងទៅឯកអគ្គរាជទូតបារាំង ដោយការធ្វើអន្តរាគមន៍ពីស្ថានទូតបារាំង ដើម្បីធ្វើការពន្យល់អាជ្ញាធរវៀតណាមថា រថយន្តនេះគ្រាន់តែបើកបរឆ្លងកាត់ប្រទេសវៀតណាម ក្នុងគោលបំណងឆ្ពោះទៅប្រទេសកម្ពុជាតែប៉ុណ្ណោះ ជាលទ្ធផលរថយន្ត ក៏ត្រូវបានសង្គ្រោះមកវិញ។

តាមកំណត់ត្រានៅក្នុងវិបសាយរបស់គាត់បានបញ្ជាក់ថា នៅមុនពេលរថយន្តត្រូវបានសង្គ្រោះ ពួកគាត់បានវិលត្រឡប់មកកម្ពុជានៅថ្ងៃទី១៣ ខែវិច្ឆិកា តាមរយៈរថយន្តក្រុងពេលមកដល់ភ្នំពេញបានខិតខំរកដំណោះស្រាយដើម្បីសង្គ្រោះរថយន្តម្តងទៀត ពួកគាត់បានទាក់ទងទៅលោក Prak ដែលជាអ្នកប្រតិបត្តិកិច្ចការស្ថានទូតបារាំងប្រចាំនៅប្រទេសកម្ពុជា ហើយលោកបាន

សន្យាថានឹងព្យាយាមជួយក្នុងរឿងនេះដែរ ប៉ុន្តែអាទិភាពសំខាន់គឺស្ថិតនៅលើអាជ្ញាធរវៀតណាម ពីព្រោះជាដែនដីត្រួតត្រារបស់គេ។ នាពេលល្ងាចពួកគាត់បានជួបជាមួយមិត្តភ័ក្ត្រជនជាតិបារាំងឈ្មោះ Anne និង Jacques ហើយបានចែករំលែកនូវបទពិសោធន៍ក្នុងការធ្វើដំណើរទៅវិញទៅមក និងជាអ្នកដែលធ្លាប់បានជួយឧបត្ថម្ភថវិកាផ្ទាល់ខ្លួនជូនដល់ពួកគាត់ទាំងពីរនូវពេលដែលជួបឧបសគ្គខ្លះខាតថវិកានៅក្នុងការធ្វើដំណើរផ្សងព្រេង។ ពួកគាត់បានពិសារអាហារពេលល្ងាចជាមួយគ្នាយ៉ាងរីករាយ បានផ្លាស់ប្តូរបទពិសោធន៍អ្នកទាំងពីរបានធ្វើដំណើរមកដល់ព្រំដែន Moc Bai ខាងភ្នាក់ងារគយជនជាតិវៀតណាមបានទាមទារនូវឯកសារពីភ្នាក់ងារប៉ូលីស ពួកគាត់បានពន្យល់ថា អាជ្ញាធរនៅតាមព្រំដែន Lang Son មិនបានប្រគល់ឯកសារទាំងនេះទេ ហេតុនេះមិនចាំបាច់ប្រើប្រាស់ឯកសារពីប៉ូលីសឡើយខាងអាជ្ញាធររបស់វៀតណាមបានពិភាក្សាគ្នា រួចហើយក៏អនុញ្ញាតឱ្យពួកគាត់ឡើងជិះរថយន្តបន្ត។ នៅតាមព្រំដែនកម្ពុជាពួកគាត់បានឆ្លងកាត់ភ្នាក់ងារអន្តោប្រវេសន៍ដោយគ្មានបញ្ហា ប៉ុន្តែជាថ្មីម្តងទៀតនៅខាងភ្នាក់ងារកម្ពុជាក៏បានទាមទារនូវលិខិតថតចំលងពណ៌ខ្សែវែងនៅក្នុងដែនដីវៀតណាម តាមការណែនាំរបស់ភ្នាក់ងារគយកម្ពុជាពួកគាត់ក៏រឹលត្រឡប់ទៅទឹកដីវៀតណាមម្តងទៀត ពួកគាត់បានចូលក្នុងទឹកដីវៀតណាមអស់មួយគីឡូម៉ែត្រ និងត្រឡប់មកវិញ ជាមួយលិខិតដែលមានបោះត្រានៅក្នុងដៃ។ (មានតនៅលេខក្រោយ)


ក្រុមចល័តជួសជុលតួរថយន្ត
និងសំអាតដោយដៃ
Mobile Auto Body & Details Hand Washed
Foreign – Domestic
Owner: Gus 267-505-7842

Call for Free Estimate
We can come out to your home or work place
យើងអាចចេញទៅធ្វើការនៅផ្ទះ ឬកន្លែងធ្វើការលោកអ្នក
Most Work Done Same Day
Most Job Under $500
We buy your Junk Cars
Top $$ Paid!
1613 S. 7th St. Philadelphia, PA 19147
នៅទល់មុខសមាគមព្រីទ្ធាចារ្យ

ផ្សះថស្ថាន TRX PHARMACY
ម្ចាស់ហាង : ស៊ីរ៉ូ អេង
ថើប
បើកថ្មី
ហាងលក់ផ្សះតម្លៃមួយជុំណ្តារឡើង
BEN CITY SUPERMARKET PLAZA
5520 WHITAKER AVENUE UNIT C
PHILADELPHIA. PA 19124
"មានជួនរង្វានីវិតាមីន១ដបនៅពេលផ្ទេរវេជ្ជបញ្ជា"
▸ ចុះថ្លៃ ១០% លើ VITAMINS រាល់ថ្ងៃព្រហស្បត្តិ៍
▸ ផ្តល់ថ្នាំព្យាបាលនឹងរបស់ប្រើប្រាស់សំរាប់សុខភាព
▸ យើងទទួលស្គើរគ្រប់ អ៊ិនស្ពរិន ទាំងអស់
▸ ធ្វើលិខិតឆ្លងដែន-ថតរូប
▸ Fax & Copies
▸ លក់ឆ្នោតផ្សេងៗ
215-288-8703
ចុះថ្លៃ 20% បើយក
បំណុំខ្មែរប៊ុស្តិ៍មកជាមួយ